# ក្រសួងអប់រំ យុវជន និងកីឡា

# ស្តង់ដាសាលាមធ្យមសិក្សាគំរូ




នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ
២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ១២៧៧ អយក.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តស្តង់ដាសាលាមធ្យមសិក្សាគំរូ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- តាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ១** .

ត្រូវបានដាក់ឱ្យអនុវត្តស្តង់ដាសាលាមធ្យមសិក្សាគំរូ សម្រាប់ជាប្រយោជន៍ក្នុងការអភិវឌ្ឍសាលាមធ្យមសិក្សាចំណោះទូទៅសាធារណៈ នៅទូទាំងប្រទេសកម្ពុជា។

**ប្រការ២** .

ស្តង់ដាសាលាមធ្យមសិក្សាគំរូ រួមមានៈ

ស្តង់ដាទី១. លទ្ធផលសិក្សារបស់សិស្ស

ស្តង់ដាទី២. ការបង្រៀននិងរៀន

ស្តង់ដាទី៣. ការចូលរួមរបស់សហគមន៍



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ស្តង់ដាទី៤. ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន

ស្តង់ដាទី៥. គណនេយ្យភាពរបស់សាលារៀន។

ខ្លឹមសារទាំងស្រុងនៃស្តង់ដាសាលាមធ្យមសិក្សាគំរូជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .**

អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយក នៃអគ្គនាយកដ្ឋានកីឡា អគ្គនាយក នៃអគ្គនាយកដ្ឋានយុវជន អគ្គនាយក នៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានធានាគុណភាពអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងប្រធានអង្គភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

# បុព្វកថា

គោលដៅនៃការអប់រំគឺ កសាងមូលធនមនុស្សប្រកបដោយភាពជាពលរដ្ឋពេញលេញ និងភាពជាពលរដ្ឋសកល តាមរយៈការផ្តល់សេវាអប់រំប្រកបដោយគុណភាព។ ការពង្រឹងគុណភាពអប់រំ ត្រូវធ្វើឡើងនៅគ្រប់ដំណាក់កាលនៃការលូតលាស់របស់កុមារ ក្នុងនោះការអប់រំនៅកម្រិតមធ្យមសិក្សានឹងផ្តោតលើការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្សានុសិស្សឱ្យប្រកបដោយចំណេះដឹង បំណិននិងជំនាញសតវត្សទី២១ និងមានសីលធម៌និងឥរិយាបថល្អ ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់បន្តការសិក្សាទៅកម្រិតឧត្តមសិក្សា។

នៅក្នុងរាជរដ្ឋាភិបាលអាណត្តិទី ៧ នៃរដ្ឋសភា ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់អាទិភាពក្នុងការបន្តធ្វើកំណែទម្រង់សាលារៀន ដែលក្នុងនោះក្រសួងនឹងពង្រឹងការគ្រប់គ្រងតាមសាលារៀនឆ្ពោះទៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ការផ្លាស់ប្តូរវប្បធម៌សាលារៀន និងការពង្រឹងវិន័យ សីលធម៌ ចរិយាធម៌ សុជីវធម៌ គុណធម៌ និងឥរិយាបថល្អរបស់បុគ្គលិកអប់រំនិងសិស្សានុសិស្ស។

ដើម្បីលើកកម្ពស់គុណភាពនៅកម្រិតមធ្យមសិក្សា ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំស្តង់ដាសាលាមធ្យមសិក្សាគំរូ ក្នុងគោលដៅពង្រឹងអភិបាលកិច្ចសាលារៀន ផ្តោតលើការកែលម្អការសិក្សារបស់សិស្ស និងការបង្កើនការចូលរួមរបស់មាតាបិតា និងសហគមន៍នៅក្នុងការអភិវឌ្ឍសាលារៀន។

ស្តង់ដាសាលាមធ្យមសិក្សាគំរូ ជារូបភាពពេញលេញមួយនៃដំណើរការ និងការអភិវឌ្ឍសាលារៀន តាមស្តង់ដាចំនួន ៥ គឺ៖ ស្តង់ដាទី១. លទ្ធផលសិក្សារបស់សិស្ស, ស្តង់ដាទី២. ដំណើរការបង្រៀន និងរៀន, ស្តង់ដាទី៣. ការចូលរួមរបស់សហគមន៍, ស្តង់ដាទី៤. ដំណើរការប្រតិបត្តិនិងរដ្ឋបាលសាលារៀន, និង ស្តង់ដាទី៥. គណនេយ្យភាព។ ឯកសារដែលបានកសាងនេះ នឹងក្លាយជាឯកសារដ៏មានសារៈប្រយោជន៍សម្រាប់គ្រប់ភាគីពាក់ព័ន្ធប្រើប្រាស់ជាខ្នាតគំរូ ក្នុងការអភិវឌ្ឍសាលាមធ្យមសិក្សា។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមថ្លែងអំណរគុណចំពោះ ថ្នាក់ដឹកនាំ បុគ្គលិកអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានខិតខំអស់កម្លាំងកាយ ចិត្ត ប្រាជ្ញា និងស្មារតី ចូលរួមរៀបចំឯកសារនេះឱ្យបានសម្រេចជាផ្លែផ្កាឡើង ក្នុងគោលដៅរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្ស សម្រាប់កសាងសង្គមកម្ពុជាឱ្យមានវិបុលភាព និងការអភិវឌ្ឍជានិរន្តរន៍។

ថ្ងៃព្រហស្បតិ៍ ១ រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# មាតិកា


ប្រកាស....I

បុព្វកថា....III

មាតិកា....IV

១. សេចក្តីផ្តើម....1

២. គោលបំណង....2

៣. គោលដៅ....2

៤. ស្តង់ដាសាលាមធ្យមសិក្សាគំរូ....3

៤.១. ការរៀបចំស្តង់ដា....3

៤.២. សូចនាករនៃស្តង់ដាសាលាមធ្យមសិក្សាគំរូ....3

៤.៣. កម្រិតផ្ទៀងផ្ទាត់សូចនាករ....3

៤.៤. ការផ្ទៀងផ្ទាត់លទ្ធផល....3

៥. តារាងស្តង់ដាសាលាមធ្យមសិក្សាគំរូ....4

៦. គោលការណ៍ណែនាំស្តង់ដាសាលាមធ្យមសិក្សាគំរូ....27

ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស....27

ស្តង់ដាទី២៖ ការបង្រៀននិងរៀន....29

ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍....34

ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន....36

ស្តង់ដាទី៥ ៖ គណនេយ្យភាព....42

៧. ការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ....43

៧.១. ឧបករណ៍វាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ....44

៧.២. របៀបនៃការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ....44

៧.៣. គំរូនៃការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ....45

៨. បែបបទនិងនីតិវិធីនៃការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ....45

៨.១. គោលការណ៍ទូទៅ និងលក្ខណៈវិនិច្ឆ័យ....45

៨.២. យន្តការ បែបបទ និងនីតិវិធី....46

*៨.២.១ សាលាមធ្យមសិក្សា....46*

*៨.២.២ រដ្ឋបាលក្រុង ស្រុក ខណ្ឌ....46*

*៨.២.៣ មន្ទីរអប់រំ យុវជន និងកីឡា....47*

*៨.២.៤ ក្រសួងអប់រំ យុវជន និងកីឡា* ........ *48*

**៩. សេចក្តីសន្និដ្ឋាន** ........ **49**

**ឧបសម្ព័ន្ធ** ........ **50**

**សូចនាករស្តង់ដាសាលាមធ្យមសិក្សាបឋមភូមិគំរូ** ........ 51

**សូចនាករស្តង់ដាសាលាមធ្យមសិក្សាទុតិយភូមិគំរូ** ........ 83

## ១. សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តវិធានការកំណែទម្រង់វិស័យអប់រំចាប់តាំងពីឆ្នាំ២០១៤ ជាបួនដំណាក់កាល រួមមានដំណាក់កាលទី១ កំណែទម្រង់ថ្នាក់ជាតិ នៅឆ្នាំ២០១៤, ដំណាក់កាលទី២ កំណែទម្រង់កម្រិតសាលារៀនពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨, ដំណាក់កាលទី៣ កំណែទម្រង់ការកសាងប្រព័ន្ធ និងអភិវឌ្ឍធនធានមនុស្សឈរលើសសរស្តម្ភ៥ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២, និងដំណាក់កាលទី៤ កំណែទម្រង់ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់បរិវត្តកម្មសេដ្ឋកិច្ចឌីជីថលចាប់ពីឆ្នាំ២០២២។ វិធានការលើកកម្ពស់គុណភាព និងភាពឆ្លើយតបរបស់សេវាអប់រំតាមរយៈការលើកកម្ពស់វិជ្ជាជីវៈ គ្រូបង្រៀន និងការលើកទឹកចិត្ត ព្រមទាំងបង្កើនស្វ័យភាព គណនេយ្យភាព និងភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសេវាអប់រំគ្រប់លំដាប់ថ្នាក់ សំដៅសម្រេចគោលដៅការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ គោលដៅទី៤.២ បានកំណត់ថា ត្រឹមឆ្នាំ២០៣០ ធានាថាសិស្សទាំងអស់ទទួលបានការអប់រំកម្រិតមធ្យមសិក្សាប្រកបដោយគុណភាព ដូច្នេះពួកគេត្រៀមខ្លួនជាស្រេចសម្រាប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ និងឈានទៅបន្តការសិក្សានៅឧត្តមសិក្សាបន្តទៀត។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៤៨ បានកំណត់ថា រដ្ឋធានារក្សាការពារ សិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ចនិងកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។

រាជរដ្ឋាភិបាល បាននិងកំពុងជំរុញការអភិវឌ្ឍសាលារៀនឱ្យមានលក្ខណៈសមស្របជាសាលាកុមារមេត្រី។ រាជរដ្ឋាភិបាលបានដាក់ចេញវិធានការ ដើម្បីលើកកម្ពស់គុណភាពអប់រំដោយផ្តោតការពង្រឹងគុណភាពសាលារដ្ឋចាប់ពីកម្រិតមត្តេយ្យសិក្សា ដល់មធ្យមសិក្សា តាមរយៈការពង្រឹងកិច្ចការសំខាន់ៗរួមមានៈ

ទី ១. ការពង្រឹងអភិបាលកិច្ចសាលារៀន

ទី២. ការពិនិត្យ កែសម្រួលនិងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស

ទី ៣. ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្សតាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា

ទី៤. ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុងការអប់រំស្របតាមពាក្យស្លោក "ភាពជាដៃគូ រដ្ឋ និងសហគមន៍ ដើម្បីការអប់រំ" Public-Community Partnership for Education ( PCPE )។

ផ្អែកតាមលទ្ធផលនៃការពិនិត្យតាមដានពាក់កណ្តាលអាណត្តិ ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣។ ក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលគោលនយោបាយចំនួនពីរគឺៈ ១) ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញ

មួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា និង ២) ពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់តួនាទីក្នុងការគ្រប់គ្រងដំណើរការសាលាមធ្យមសិក្សាទូទាំងប្រទេសឱ្យមានប្រសិទ្ធភាព ឆ្លើយតបនឹងតម្រូវការរៀនសូត្ររបស់កុមារប្រកបដោយគុណភាព។

អនុវត្តតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ស្តីពីការអប់រំ និងគោលដៅការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ ជាពិសេសយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលារៀន។ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវស្តង់ដាសាលាមធ្យមសិក្សាគំរូ ដែលជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពសាលាមធ្យមសិក្សា ដោយផ្តោតលទ្ធផលសិក្សារបស់សិស្ស ការបង្រៀន និងរៀន ការចូលរួមរបស់សហគមន៍ ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន និងគណនេយ្យភាពរបស់សាលារៀន ដែលរួមមានស្តង់ដាចំនួន ៥ សូចនាករគោលចំនួន ២៦ និងសូចនាកររង ៨២ (នៅមធ្យមសិក្សាបឋមភូមិ) និង៨៣ (នៅមធ្យមសិក្សាទុតិយភូមិ) សម្រាប់វាស់វែង។

## ២. គោលបំណង

ស្តង់ដាសាលាគំរូ មានគោលបំណងពង្រឹងស្វ័យគ្រប់គ្រងសាលាមធ្យមសិក្សា និងផ្តល់សេវាអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន ប្រសិទ្ធភាព និងចីរភាព ដើម្បីផ្តល់ឱកាសឱ្យសិស្សានុសិស្សមានបំណិនខ្ពស់សម្រាប់ជីវិតនិងការងារ និងត្រៀមគេរួចជាស្រេចបន្តការសិក្សានៅកម្រិតឧត្តមសិក្សា ឬចូលក្នុងទីផ្សារការងារ ។

## ៣. គោលដៅ

ស្តង់ដាសាលាមធ្យមសិក្សាគំរូមានគោលដៅ៖

- ពង្រឹងសមត្ថភាពដល់គណៈគ្រប់គ្រងសាលាមធ្យមសិក្សា លើការងារគ្រប់គ្រងនិងដឹកនាំ និងគ្រប់អ្នកពាក់ព័ន្ធឱ្យយល់ដឹងអំពីការងារដែលមធ្យមសិក្សាត្រូវធ្វើ គឺដើម្បីពង្រឹងប្រសិទ្ធភាពនៃការបង្រៀន និងរៀន និងកែលម្អគុណភាពនៃការសិក្សាឱ្យមានភាពឆ្លើយតប
- វាស់វែងពីកម្រិតប្រសិទ្ធភាពការងារ និងគុណភាពអប់រំមធ្យមសិក្សា
- ធានាគុណភាព និងនិរន្តរភាពនៃមធ្យមសិក្សា។

## ៤. ស្តង់ដាសាលាមធ្យមសិក្សាគំរូ

### ៤.១. ការរៀបចំស្តង់ដា

ដើម្បីឆ្លើយតបនឹងកំណែទម្រង់ការគ្រប់គ្រងសាលារៀន ស្របតាមការសម្រេចអាទិភាពនៃកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាសម្រាប់ឆ្នាំ២០២៣-២០២៨ ឱ្យមានគុណភាព សមធម៌ បរិយាបន្ន ប្រសិទ្ធភាព និងចីរភាព ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់នូវស្តង់ដាសាលាមធ្យមសិក្សាគំរូចំនួន ៥ ដូចខាងក្រោម៖

ស្តង់ដាទី១. លទ្ធផលសិក្សារបស់សិស្ស
ស្តង់ដាទី២. ការបង្រៀននិងរៀន
ស្តង់ដាទី៣. ការចូលរួមរបស់សហគមន៍
ស្តង់ដាទី៤. ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន
ស្តង់ដាទី៥. គណនេយ្យភាពរបស់សាលារៀន។

### ៤.២. សូចនាករនៃស្តង់ដាសាលាមធ្យមសិក្សាគំរូ

ក្នុងការវាស់វែងស្តង់ដាទាំង៥ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់សូចនាករ ៨២(នៅមធ្យមសិក្សាបឋមភូមិ) ៨៣ (នៅមធ្យមសិក្សាទុតិយភូមិ) ដែលក្នុងនោះ **ស្តង់ដាទី១** មានសូចនាករគោល ៥ និងសូចនាកររង ២០ (នៅមធ្យមសិក្សាបឋមភូមិ) ២១ (នៅមធ្យមសិក្សាទុតិយភូមិ), **ស្តង់ដាទី២** មានសូចនាករគោល ៩ និងសូចនាកររង ២៩, **ស្តង់ដាទី៣** មានសូចនាករគោល ៣ និងសូចនាកររង ៦, **ស្តង់ដាទី៤** មានសូចនាករគោល ៦ និងសូចនាកររង ២៣ , **ស្តង់ដាទី៥** មានសូចនាករគោល ៣ និងសូចនាកររង ៤។

### ៤.៣. កម្រិតផ្ទៀងផ្ទាត់សូចនាករ

កម្រិតផ្ទៀងផ្ទាត់សូចនាករ ជាការកំណត់ពីលទ្ធផលតាមបែបគុណវិស័យ ឬបរិមាណវិស័យ ស្របតាមទិដ្ឋភាពជាក់ស្តែងនៃសូចនករនីមួយៗ ដើម្បីចង្អុលបង្ហាញពីកម្រិតវាស់វែងការអនុវត្តសូចនាករដូចមានបង្ហាញក្នុងតារាងស្តង់ដាសាលាមធ្យមសិក្សាគំរូខាងក្រោម។

### ៤.៤. ការផ្ទៀងផ្ទាត់លទ្ធផល

ការផ្ទៀងផ្ទាត់លទ្ធផល គឺជាការវាយតម្លៃលើការអនុវត្តកម្រិតសូចនាករទាំង៨២ឬ៨៣ ដោយដាក់ពិន្ទុផ្អែកលើភស្តុតាងសូចនាករនីមួយៗ ដែលមានពិន្ទុសរុប ៤១០ ឬ៤១៥ពិន្ទុ ស្មើនឹង១០០%។ ការកំណត់ថាមានឬមិនទាន់មានលក្ខណៈគំរូ ត្រូវបានកំណត់ដូចខាងក្រោម៖

- សាលាមធ្យមសិក្សាអនុវត្តលទ្ធផលសម្រេចបានចាប់ពី ៩៥% ឡើងទៅ នឹងត្រូវចាត់ទុកថា មានស្តង់ដាពេញលេញ

- សាលាមធ្យមសិក្សាអនុវត្តលទ្ធផលសម្រេចបានចាប់ពី ៨០% ដល់តិចជាង ៩៥% ត្រូវចាត់ទុកថា មានស្តង់ដា
- សាលាមធ្យមសិក្សាអនុវត្តលទ្ធផលសម្រេចបានចាប់ពី ៦០% ដល់តិចជាង ៨០% ត្រូវចាត់ទុកថា មានស្តង់ដាអប្បបរមា។

សាលាមធ្យមសិក្សាដែលទទួលលទ្ធផលចាប់ពីស្តង់ដាអប្បបរមាឡើងទៅ មានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។ ការផ្ទៀងផ្ទាត់លទ្ធផលត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

**ជំហានទី១**. ពិនិត្យផ្ទៀងផ្ទាត់ផ្អែកលើភស្តុតាង ដាក់កំណត់ត្រាលទ្ធផលជាក់ស្តែងនៃលទ្ធផលសូចនាករនីមួយៗ។

**ជំហានទី២**. របៀបដាក់ពិន្ទុ ប្រសិនបើភស្តុតាងធៀបទៅនឹងកម្រិតផ្ទៀងផ្ទាត់សូចនាករ បានគ្រប់ចំណុចនិងត្រឹមត្រូវ នោះនឹងទទួលបាន ៥ពិន្ទុ តាមសូចនាករនោះ។

## ៥. តារាងស្តង់ដាសាលាមធ្យមសិក្សាគំរូ

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| **ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស** | | | | |
| ១. ការប្រមូលកុមារចូលរៀន | | | | |
| ១.១ | ភាគរយសិស្សថ្នាក់ទី៧ បានចូលរៀន | - សាលារៀន មានផែនទីសិក្សា/ទិន្នន័យសិក្សា / សៀវភៅគ្រួសារ បង្ហាញទិន្នន័យសិស្សចូលរៀន (កម្រិតថ្នាក់ និងកម្រិតភូមិ)<br>- សាលារៀន មានតារាងស្ថិតិសិស្សមកពីសាលា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិចំណុះ តាមឆ្នាំសិក្សានីមួយៗ (តារាង Excel) | | |
| ២. សិស្សរៀនបានគង់វង្សក្នុងសាលារៀន | | | | |
| ២.១ | ភាគរយសិស្សបោះបង់ការសិក្សា | - សាលារៀនមានតារាង / បញ្ជីឈ្មោះសិស្សលម្អិតតាមកម្រិតថ្នាក់ និងស្ថានភាពគ្រួសារ (កម្រិតថ្នាក់ និងកម្រិតភូមិសិក្សា) | | |
| ៣. លទ្ធផលសិក្សារបស់សិស្ស | | | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| ៣.១ | ភាគរយសិស្សឡើងថ្នាក់ | - សាលារៀន មានតារាង / បញ្ជីឈ្មោះសិស្សលម្អិតឡើង ថ្នាក់តាមកម្រិតថ្នាក់ និងកម្រិតភូមិសិក្សា រួមជាមួយនឹងមធ្យមភាគពិន្ទុប្រចាំឆ្នាំនៃសិស្សម្នាក់ៗ | | |
| ៣.២ | ភាគរយសិស្សទទួលបានលទ្ធផលសិក្សានិទ្ទេសA B C មុខវិជ្ជាភាសាខ្មែរ គ្រប់កម្រិតថ្នាក់ | - កាលវិភាគអនុវត្តតេស្តស្តង់ដាសម្រាប់ឆ្នាំសិក្សា (កម្រិតសាលា)<br>- អនុវត្តតេស្តស្តង់ដាប្រចាំខែ ត្រីមាស ឆមាស និងដំណាច់ឆ្នាំ (កម្រិតសាលា)<br>- តារាងលទ្ធផលបង្រៀនរបស់គ្រូតាមមុខវិជ្ជា និងកម្រិតថ្នាក់ ដែលបង្ហាញពីចំនួនសិស្សសរុបជាប់ និងធ្លាក់ ប្រចាំខែ និងដំណាច់ឆ្នាំ (ក្រុម ICT /គណៈគ្រប់គ្រងសាលារៀន /ប្រធានក្រុមបច្ចេកទេស)<br>- សាលារៀន បានបិទផ្សាយជាសាធារណៈនូវលទ្ធផលសិក្សារបស់សិស្សប្រចាំខែ និងលទ្ធផលបង្រៀនរបស់គ្រូម្នាក់ៗ<br>- របាយការណ៍នៃការធ្វើតេស្តចុងឆ្នាំសិក្សា ដោយបូកសរុប ចំនួនសិស្សថ្នាក់ទី៧ ដល់ទី៩ មាននិទ្ទេស ABនិងC តាមមុខវិជ្ជា ចែកនឹងចំនួនសិស្សសរុបក្នុងសាលារៀន | | |
| ៣.៣ | ភាគរយសិស្សទទួលបានលទ្ធផលសិក្សានិទ្ទេសA B C មុខវិជ្ជាគណិតវិទ្យាគ្រប់កម្រិតថ្នាក់ | | | |
| ៣.៤ | ភាគរយសិស្សទទួលបានលទ្ធផលសិក្សា និទ្ទេសA B C មុខវិជ្ជារូបវិទ្យា គ្រប់កម្រិតថ្នាក់ | | | |
| ៣.៥ | ភាគរយសិស្សទទួលបានលទ្ធផលសិក្សា និទ្ទេសA B C មុខវិជ្ជាគីមីវិទ្យា គ្រប់កម្រិតថ្នាក់ | | | |
| ៣.៦ | ភាគរយសិស្សទទួលបានលទ្ធផលសិក្សានិទ្ទេសA B Cមុខវិជ្ជាជីវវិទ្យាគ្រប់កម្រិតថ្នាក់ | | | |
| ៣.៧ | ភាគរយសិស្សទទួលបានលទ្ធផលសិក្សា | | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | គស្តុតាង | ពិន្ទុ |
| | និទ្ទេសA B C មុខវិជ្ជាផែនដី-បរិស្ថាន វិទ្យាគ្រប់កម្រិតថ្នាក់ | | | |
| ៣.៨ | ភាគរយសិស្សទទួលបានលទ្ធផលសិក្សានិទ្ទេសA B C មុខវិជ្ជាប្រវត្តិវិទ្យាគ្រប់កម្រិតថ្នាក់ | | | |
| ៣.៩ | ភាគរយសិស្សទទួលបានលទ្ធផលសិក្សានិទ្ទេសA B C មុខវិជ្ជាភូមិវិទ្យាគ្រប់កម្រិតថ្នាក់ | | | |
| ៣.១០ | ភាគរយសិស្សទទួលបានលទ្ធផលសិក្សានិទ្ទេសA B C មុខវិជ្ជាសីលធម៌-ពលរដ្ឋវិទ្យាគ្រប់កម្រិតថ្នាក់ | | | |
| ៣.១១ | ភាគរយសិស្សទទួលបានលទ្ធផលសិក្សានិទ្ទេសA B C មុខវិជ្ជាភាសាបរទេសគ្រប់កម្រិតថ្នាក់ | | | |
| ៣.១២ | ភាគរយសិស្សថ្នាក់ទី៨ មាន សមត្ថភាពអានតាមស្តង់ដា (១៥០ ទៅ១៨០ពាក្យក្នុងមួយនាទី)<br><br>ភាគរយសិស្សថ្នាក់ទី១០ | - ថ្នាក់រៀនមានកាលវិភាគ សម្រាប់កម្មវិធីប្រកួតក្រុមសិស្សអានស្ទាត់/ល្បឿនអំណានអត្ថបទគ្រប់មុខវិជ្ជា ប្រចាំសប្តាហ៍ ដើម្បីជ្រើសរើសក្រុមសិស្សឆ្នើម កម្រិតថ្នាក់រៀន និងកម្រិតសាលារៀន (ប្រធានក្រុមបច្ចេកទេស)<br>- គ្រូបង្រៀនភាសាខ្មែរ មានតេស្តបំណិន | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតឆ្លៀងផ្ទាត់សូចនាករ | កម្រិតឆ្លៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | មានសមត្ថភាពអានតាមស្តង់ដា (២០០ទៅ២៥០ពាក្យក្នុងមួយនាទី) | អានស្ទាត់ (១) ឯកសារកិច្ចការសិស្ស តេស្តប្រចាំខែអំណាន (២) សន្លឹកកិច្ចការសម្រាប់សិស្សអាន (៣) ឯកសារណែនាំអនុរក្សតេស្តប្រចាំខែអំណាន និងអត្ថបទអំណានស្ទាត់ភាសាខ្មែរ<br>- របាយការណ៍នៃតេស្តអំណានស្ទាត់ ចុងឆ្នាំសិក្សាដោយបូកសរុបចំនួនសិស្សថ្នាក់ទី៨ ដែលមានសមត្ថភាពអំណានតាមស្តង់ដា ដោយល្បឿនចាប់ពី១៥០ ទៅ១៨០ ពាក្យក្នុង១នាទីឡើងទៅ ចែកនឹងចំនួនសិស្សថ្នាក់ទី៧សរុបក្នុងសាលារៀន<br>- របាយការណ៍នៃតេស្តអំណានស្ទាត់ ចុងឆ្នាំសិក្សាដោយបូកសរុបចំនួនសិស្សថ្នាក់ទី១០ ដែលមានសមត្ថភាពអំណានតាមស្តង់ដា ដោយល្បឿនចាប់ពី២០០ ទៅ២៥០ ពាក្យក្នុង១នាទីឡើងទៅ ចែកនឹងចំនួនសិស្សថ្នាក់ទី១០សរុបក្នុងសាលារៀន | | |
| ៣.១៣ | ភាគរយសិស្សប្រឡងជាប់ សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | - បញ្ជីឈ្មោះសិស្សប្រឡងថ្នាក់ទី៩<br>- បញ្ជីឈ្មោះលទ្ធផលប្រឡងជាប់ និងធ្លាក់សិស្សថ្នាក់ទី៩ រួមនឹងកម្រិតនៃនិទ្ទេស ល្អប្រសើរ ល្អ ល្អបង្គួរ មធ្យម | | |
| **៤. ស្ថានភាពអាហារូបត្ថម្ភ (ការគាំទ្រផ្នែក សុខភាពនិងសុវត្ថិភាពសិក្សា)** | | | | |
| ៤.១ | ភាគរយសិស្សមានស្ថានភាពអាហារូបត្ថម្ភធម្មតា | – បញ្ជីកត់ត្រាស្ថានភាពអាហារូបត្ថម្ភសិស្ស (អាយុ ទម្ងន់ កម្ពស់)<br>– សៀវភៅតាមដានសុខភាពសិស្សម្នាក់ៗ | | |
| ៤.២ | ភាគរយសិស្សដែលមានបញ្ហាអាហារូបត្ថម្ភទទួលបាន កិច្ចអន្តរាគមន៍ | – របាយការណ៍ត្រឡប់ពីមាតាបិតាឬអ្នកអាណាព្យាបាល ក្នុងការសហការជួយអន្តរាគមន៍ ឬការនាំកុមារទៅរកសេវាគាំទ្រ | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | | – របាយការណ៍ពីកិច្ចអន្តរាគមន៍របស់សេវាសុខាភិបាលមូលដ្ឋាន តាមរយៈគណៈកម្មការសុខភាពសិក្សា តាមសាលារៀន | | |
| ៤.៣ | ភាគរយសិស្សក្រីក្រ សិស្សជួបការលំបាក ឬ គ្រួសារងាយរងគ្រោះ ត្រូវបានជួយគាំទ្រពីកម្មវិធីនានា របស់សាលារៀន | – សាលារៀនមានបញ្ជី និងទិន្នន័យច្បាស់លាស់ ពីចំនួន សិស្សក្រីក្រ សិស្សជួបការលំបាក យ៉ាប់យ៉ឺន ឬ គ្រួសារងាយរងគ្រោះ បានជួយគាំទ្រពីកម្មវិធីនានា របស់ សាលារៀន និងអាជ្ញាធរដែនដី | | |
| **៥. សីលធម៌ និងឥរិយាបថរបស់សិស្ស** | | | | |
| ៥.១ | ភាគរយកុមារទទួលបានការប្រឹក្សាយោបល់ | – របាយការណ៍អំពីចំនួនករណីហិង្សា ឬ វិបត្តិផ្លូវចិត្តនានា<br>– របាយការណ៍អំពីចំនួនកុមារដែលរងហិង្សា ឬ មានវិបត្តិផ្លូវចិត្ត បានទទួលប្រឹក្សាយោបល់ | | |
| ៥.២ | ភាគរយថ្នាក់រៀនដាក់ពិន្ទុ បំណិនសម្បទា និងចរិយាសម្បទាដល់សិស្សប្រចាំឆ្នាំ | – របាយការណ៍អំពីចំនួនថ្នាក់រៀនដែលបានដាក់ពិន្ទុបំណិនសម្បទា និងចរិយាសម្បទាដល់សិស្សប្រចាំឆ្នាំ ធៀបជាមួយចំនួនថ្នាក់រៀនសរុប<br>– ផ្ទៀងផ្ទាត់ជាមួយបញ្ជីពិន្ទុ សៀវភៅតាមដានការសិក្សា និងសៀវភៅសិក្ខាគារិក | | |
| **ស្តង់ដាទី២៖ ដំណើរការបង្រៀន និងរៀន** | | | | |
| **១. ការអនុវត្តវិធីសាស្ត្របង្រៀនថ្មី** | | | | |
| ១.១ | ចំនួនសិស្សបានធ្វើកិច្ចការគម្រោង/សំណួរ/ចំណោទ/លំហាត់ | - សិស្សមានសន្លឹកកិច្ចការស្វ័យសិក្សាមុនពេលជួបគ្រូបង្រៀន<br>- សាលារៀនមានបញ្ជីកត់ត្រាអំពី ចំនួនសិស្សបានធ្វើកិច្ចការគម្រោងទាំងអស់/ | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតឆ្លៀងផ្ទាត់សូចនាករ | កម្រិតឆ្លៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | | សំណួរ/ចំណោទ/លំហាត់ | | |
| ២. ការអនុវត្តកម្មវិធីសិក្សានិងការរៀបចំផែនការបង្រៀន | | | | |
| ២.១ | ចំនួនថ្នាក់រៀនមានផែនការបង្រៀន៣ឆ្នាំតាមមុខវិជ្ជា | - ថ្នាក់រៀនមានផែនការបង្រៀន៣ឆ្នាំ និង១ឆ្នាំ តាមមុខវិជ្ជា (ប្រធានក្រុមបច្ចេកទេស)<br>- បង្រៀនទាន់តាមកម្មវិធី និងផែនការដែលបាន គ្រោងទុក | | |
| ២.២ | ភាគរយថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា | - ថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់ (ប្រធានក្រុមបច្ចេកទេស) | | |
| ២.៣ | ចំនួនថ្នាក់ដែលមានបំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជា ប្រចាំសប្តាហ៍ ប្រចាំខែ និងឆ្នាំ | - សាលារៀនមានតារាងបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំខែនិងសប្តាហ៍ តាមមុខវិជ្ជា  និងតាមកម្រិតថ្នាក់<br>- សាលារៀនមានផែនការបង្រៀនប្រចាំថ្ងៃតាមកាលវិភាគប្រចាំសប្តាហ៍ ផែនការបង្រៀន ៣ខែម្តង | | |
| ២.៤ | ចំនួនមុខវិជ្ជា ដែលគ្រូបង្រៀនតាមមុខវិជ្ជាពីថ្នាក់ទី៧ដល់៩មានកិច្ចតែងការបង្រៀន(មុខវិជ្ជា) | - គ្រូតាមមុខវិជ្ជាម្នាក់ៗគ្រប់កម្រិតថ្នាក់ ត្រូវធ្វើកិច្ចតែងការ បង្រៀន/គម្រោងបង្រៀនមួយមេរៀនមានច្រើនម៉ោង (ប្រធានក្រុមបច្ចេកទេស និងនាយករង ទទួលបន្ទុកបច្ចេកទេស) | | |
| ២.៥ | ចំនួនដងគ្រូអវត្តមាននិងមិនមានគ្រូជំនួស | - សាលារៀនមានបញ្ជីកត់ត្រាចំនួនដងនៃគ្រូម្នាក់ៗនៅពេលអវត្តមាន<br>- សាលារៀនមានលិខិតអនុញ្ញាតច្បាប់ | | |
| ២.៦ | ចំនួនថ្ងៃសាលាបិទទ្វារមិនតាមការឈប់ប្រតិទិនសម្រាកប្រចាំឆ្នាំ | - សាលារៀនមានកំណត់ហេតុឬរបាយការណ៍ពីការផ្អាក ដំណើរការបង្រៀន និងរៀន<br>- ផ្តល់ព័ត៌មានទៅការិយាល័យអប់រំនែ | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | តស្លុតាង | ពិន្ទុ |
| | | រដ្ឋបាលក្រុង ស្រុក ខណ្ឌនៅពេលសាលារៀន បិទទ្វារ | | |
| ២.៧ | ភាគរយសិស្សមាននិងអនុវត្តការ តាមដានផែនការសិក្សារៀនសូត្រប្រចាំឆ្នាំសិក្សា | - សិស្សមានផែនការសិក្សារៀនសូត្របីខែ និងមួយឆ្នាំ មានលទ្ធផលតេស្តដើមឆ្នាំគ្រប់កម្រិតថ្នាក់តាមមុខវិជ្ជា<br>- ពិនិត្យតាមដានលទ្ធផលសិក្សាប្រចាំខែដឹកនាំដោយគ្រូបន្ទុកថ្នាក់។ សម្រាប់ថ្នាក់ទី៧ថ្មី សាលាត្រូវបង្ហាញពីលទ្ធផលតេស្តដើមឆ្នាំ លើមុខវិជ្ជាគោលភាសាខ្មែរ និងគណិតវិទ្យា។ (គ្រូបន្ទុកថ្នាក់ និងគណៈគ្រប់គ្រងសាលា) | | |
| **៣. សម្ភារះរៀននិងបង្រៀន** | | | | |
| ៣.១ | ផលធៀបសិស្ស សៀវភៅសិក្សាគោល | - សាលារៀនមានបញ្ជី និងទិន្នន័យពីចំនួនសិស្ស ដែលមានសៀវភៅសិក្សាគោលតាមការណែនាំះ មធ្យមសិក្សាបឋមភូមិ ១/១<br>- ផ្ទៀងផ្ទាត់ជាមួយសិស្សម្នាក់ៗតាមរយៈការបញ្ជាក់ពីសិស្សានុសិស្សនិងអ្នកពាក់ព័ន្ធផ្សេងទៀត | | |
| ៣.២ | ចំនួនថ្នាក់ដែលបានប្រើប្រាស់បន្ទប់កុំព្យូទ័រ | - សាលារៀនមានទិន្ន័យពីចំនួនសិស្សបានចូលប្រើប្រាស់បន្ទប់កុំព្យូទ័រ និងកត់ត្រាបានទៀងទាត់<br>- សាលារៀនមានកាលវិភាគ និងបញ្ជីកត់ត្រាអំពីដំណើរការបន្ទប់កុំព្យូទ័រ | | |
| ៣.៣ | ចំនួនថ្នាក់ដែលបានប្រើប្រាស់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ | - សាលារៀនមានទិន្ន័យពីចំនួនសិស្សបានចូលប្រើប្រាស់បន្ទប់ពិសោធន៍ និងកត់ត្រាបានទៀងទាត់<br>- សាលារៀនមានកាលវិភាគ និងបញ្ជីកត់ត្រាអំពីដំណើរការបន្ទប់ពិសោធន៍ | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | តស្តុតាង | ពិន្ទុ |
| **៤. ការជួយគាំទ្រសិស្ស** | | | | |
| ៤.១ | ភាគរយគ្រូបានដាក់លំហាត់ ឬកិច្ចការផ្ទះតាមមុខវិជ្ជាគោល | - សាលារៀនមានបញ្ជីកត់ត្រាទិន្នន័យពីចំនួនសិស្សបានទទួលលំហាត់ឬកិច្ចការផ្ទះដែលគ្រូបង្រៀនបានដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និង វិទ្យាសាស្ត្រ) ធៀបជាមួយផែនការប្រចាំឆ្នាំ<br>- សាលារៀនមានបញ្ជីកត់ត្រាទិន្នន័យពីចំនួនគ្រូបង្រៀនបានកែកិច្ចការសិស្សជាលំហាត់ឬ កិច្ចការផ្ទះ តាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និង វិទ្យាសាស្ត្រ) ធៀបជាមួយផែនការប្រចាំឆ្នាំ | | |
| ៤.២ | ភាគរយគ្រូបានកែលំហាត់ ឬកិច្ចការផ្ទះតាមមុខវិជ្ជាគោល | | | |
| ៤.៣ | ភាគរយថ្នាក់រៀនមានក្លឹបស្វ័យសិក្សាមានដំណើរការ | - សាលារៀនមានបញ្ជី ទិន្នន័យពីចំនួនក្លឹបសិក្សា និងមានដំណើការ<br>- សាលារៀនមានរបាយការណ៍ស្តីពីសិស្សបានធ្វើកិច្ចការជាគម្រោងនៃក្លឹបសិក្សាតាមរយៈការកត់ត្រាសកម្មភាព<br>- រៀបចំទុកដាក់រូបថតសកម្មភាពក្នុងកុំព្យូទ័រ | | |
| ៤.៤ | ភាគរយសិស្សរៀនយឺតមុខវិជ្ជា ភាសាខ្មែរ និងគណិត វិទ្យា | - សាលារៀនមានបញ្ជីទិន្នន័យពីចំនួនសិស្សរៀនយឺត មុខវិជ្ជា ភាសាខ្មែរ និងគណិតវិទ្យា<br>- សាលារៀនមានកាលវិភាគប្រចាំសប្តាហ៍សម្រាប់បំប៉នសិស្សរៀនយឺត មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា | | |
| **៥. ដំណើរការបណ្ណាល័យ** | | | | |
| ៥.១ | បណ្ណាល័យបានបង្កើត និងមានស្តង់ដា | - បណ្ណាល័យ ឬបន្ទប់<br>- សៀវភៅសិក្សាគោល សៀវភៅលំហាត់ សៀវភៅអំណានបន្ថែមគ្រប់កម្រិតថ្នាក់ | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | | រៀន និងសមាមាត្រទៅចំនួនសិស្សនៅក្នុងសាលា<br>- បណ្ណារក្ស និងមានកាលវិភាគចូលអានសៀវភៅ<br>- ឧបករណ៍ឌីជីថល និងអ៊ីនធើណែតសម្រាប់បម្រើការបង្រៀន និងរៀន និងស្រាវជ្រាវ | | |
| ` ៥.២ | ភាគរយសិស្សប្រើបណ្ណាល័យ (មានរបាយការណ៍ពិនិត្យតាមដានរាល់ត្រីមាស) | - បញ្ជីឈ្មោះចូលប្រើប្រាស់បណ្ណាល័យ<br>- បទបញ្ជាផ្ទៃក្នុងបណ្ណាល័យ<br>- កាលវិភាគសិស្សចូលអាន<br>- បញ្ជីឈ្មោះសៀវភៅ និងសម្ភារៈ<br>- គ្រូបង្រៀនដាក់កិច្ចការសិស្សសម្រាប់ស្រាវជ្រាវក្នុងបណ្ណាល័យ | | |
| **៦. ការធ្វើអធិការកិច្ចផ្ទៃក្នុង** | | | | |
| ៦.១ | ចំនួនដងនាយកសាលារៀនចុះធ្វើអធិការកិច្ចថ្នាក់រៀនតាមផែនការ | - សាលារៀនមានផែនការ និងរបាយការណ៍អធិការកិច្ច សង្កេតការបង្រៀន និង ការគ្រប់គ្រងថ្នាក់រៀនសម្រាប់ឆ្នាំសិក្សា<br>- មានសំណើសុំពីគ្រូបង្រៀន ដើម្បីចុះជួយ<br>- គណៈគ្រប់គ្រងសាលារៀនបានចុះធ្វើអធិការកិច្ចថ្នាក់រៀន តាមផែនការ និងមានឧបករណ៍គាំទ្រ | | |
| ៦.២ | ភាគរយគ្រូបង្រៀនទទួលបានការផ្តល់ប្រឹក្សាគរុកោសល្យ/អធិការកិច្ចថ្នាក់រៀនតាមផែនការយ៉ាងតិចមួយដងក្នុងមួយឆ្នាំ | - គ្រូបង្រៀនទទួលបានការផ្តល់ប្រឹក្សាគរុកោសល្យពីក្រុមបច្ចេកទេសសាលារៀន<br>- គ្រូបង្រៀនទទួលបានការធ្វើអធិការកិច្ចផ្ទៃក្នុងយ៉ាងតិច១ដង/១ឆ្នាំ | | |
| **៧. ការប្រជុំបច្ចេកទេស** | | | | |
| ៧.១ | ការប្រជុំបច្ចេកទេសបាន | - សាលារៀនមានផែនការប្រជុំប្រចាំខែ ឆ្នាំ | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតឆ្លៀងផ្ទាត់សូចនាករ | កម្រិតឆ្លៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | តស្គាល់ | ពិន្ទុ |
| | អនុវត្តទៀងទាត់តាមផែនការដែលបានគ្រោង | និងការប្រជុំត្រូវមានវត្ថុបំណងច្បាស់លាស់ ដើមឆ្នាំ ដំណាច់ឆមាសទី១ (ក្រុមមុខវិជ្ជានីមួយៗ ផ្តោតលើថ្នាក់រៀន នៃមុខវិជ្ជាដែលមានសិស្សធ្លាក់មធ្យមភាគច្រើនជាងគេ ដើម្បីជួយគ្រូនិងសិស្សបានទាន់ពេល)<br>- សាលារៀនមានរបាយការណ៍/កំណត់ហេតុប្រជុំ បញ្ជីវត្តមាន | | |
| ៨. ការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា | | | | |
| ៨.១ | ភាគរយថ្នាក់បានបង្រៀនភាសាបរទេសក្រៅម៉ោងសិក្សាស្របតាមកម្រិតថ្នាក់ | - សាលារៀនមានផែនសិក្សាការប្រចាំឆ្នាំលើកម្មវិធីសិក្សាភាសាបរទេស<br>- សាលារៀនមានបញ្ជីឈ្មោះគ្រូ សិស្សបង្រៀននិងរៀនភាសាបរទេស | | |
| ៨.២ | ភាគរយសិស្សបានរៀនកុំព្យូទ័រ សមស្របតាមកម្រិតថ្នាក់ | - សាលារៀនមានកាលវិភាគ និងបញ្ជីកត់ត្រាអំពី ដំណើរការបន្ទប់ កុំព្យូទ័រ និងចំនួនសិស្សបានចូលរៀន | | |
| ៨.៣ | ភាគរយថ្នាក់បានបង្រៀនបំណិន ជីវិតក្រៅម៉ោងសិក្សា ដើម្បីរកចំណូល | - សាលារៀនមានកាលវិភាគ និងបញ្ជីកត់ត្រាចំនួន គ្រូបង្រៀន សិស្សបានចូលសិក្សា និងអនុវត្តលើបំណិនកសិកម្ម និងបច្ចេកទេស និងចំនួនគ្រូបង្រៀន សិស្សទទួលបានប្រាក់ចំណូលពីការអនុវត្តបំណិន | | |
| ៨.៤ | ចំនួនដងប្រកួតប្រជែងការអានអក្សរ/ស្មូត្រ (ពិពរណ៍ស្នាដៃសិស្ស) | - ថ្នាក់រៀននីមួយៗមានបញ្ជីឈ្មោះសិស្សបានស្វ័យសិក្សា សន្លឹក កិច្ចការទី១ ទី២ ទី៣ មុនពេលរៀនជាមួយគ្រូ<br>- សាលារៀនមានផែនការ និងកម្មវិធីសម្រាប់ប្រកួត ប្រជែងការអានអក្សរ និងធ្វើលំហាត់ គណិតវិទ្យា ក្នុងកម្រិតថ្នាក់រៀនមួយ ឬរវាងថ្នាក់និងថ្នាក់ ឬរវាងភូមិសិក្សា និងភូមិសិក្សា | | |
| ៨.៥ | ចំនួនដងនៃការប្រកួតប្រជែងការធ្វើលំហាត់គណិតវិទ្យា (ពិពរណ៍ស្នាដៃសិស្ស) | | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ឥស្សតាង | ពិន្ទុ |
| | | - សាលារៀនមានកម្មវិធីលើកសសើរ និងជូនរង្វាន់ទៅតាមលទ្ធភាព និងស្ថានភាពនៃសាលារៀន | | |
| ៩. ការអនុវត្តការអប់រំសីលធម៌ ចរិយាធម៌ | | | | |
| ៩.១ | ចំនួនដងសាលារៀនបានរៀបចំកម្មវិធីលើកកម្ពស់ចរិយាធម៌ សីលធម៌ | - សាលារៀនមានកម្មវិធីអនុវត្តការអប់រំចិត្តសង្គមដល់សិស្សនិង កម្មវិធីអប់រំផ្លូវចិត្តមាតាបិតា ឬអ្នកអាណាព្យាបាល<br>- សាលារៀនមានរៀបចំកម្មវិធីសមាធិនៅពេលមុនចេញ មកផ្ទះ ឬពេលគោរពទង់ជាតិ | | |
| ៩.២ | ចំនួនដងថ្នាក់នីមួយៗបានអនុវត្តកម្មវិធីហ្វឹកហាត់កីឡា | - សាលារៀនមានផែនការ និងកាលវិភាគសិស្សបាន ចូលរួមកម្មវិធីហ្វឹកហាត់កីឡាតាមមុខសញ្ញាដែលបាន រៀបចំ ដាប្រភេទបាល់ទាត់ បាល់បោះ លោតកម្ពស់...និងមានគ្រូបង្រៀនតាមប្រភេទនៃកីឡា | | |
| ៩.៣ | សកម្មភាពសិល្បៈ (ចម្រៀង របាំ តន្ត្រី គំនូរ) | - សាលារៀនមានកាលវិភាគ កម្មវិធី និងគ្រូបង្រៀនមុខវិជ្ជា សិល្បៈ លើមុខវិជ្ជាចម្រៀង របាំ តន្ត្រី គំនូ | | |
| ៩.៤ | ភាគរយសិស្សបានចូលរួមអនុវត្ត សកម្មភាពនានាសម្រាប់អភិវឌ្ឍយុវជន | - សាលារៀនរៀបចំ បំផុស និងកត់ត្រាសកម្មភាពនានា សម្រាប់អភិវឌ្ឍយុវជនដូចជាៈ សង្ក្រានឆ្នាំថ្មី សកម្មភាពសប្បុរសធម៌ក្នុងសហគមន៍ ជួយជនចាស់ជរាគ្រួសារក្រីក្រ... | | |
| **ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍** | | | | |
| ១. ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន(គ.គ.ស)និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន(គ.គ.ថ) | | | | |
| ១.១ | ចំនួនសមាសភាពគណៈ | - សាលារៀនមានសេចក្តីសម្រេចស្តីពីការ | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតធៀបផ្ទាត់សូចនាករ | កម្រិតធៀបផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | តស្តុតាង | ពិន្ទុ |
| | កម្មការគ្រប់គ្រងសាលារៀន (គ.គ.ស) | បង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន (គ.គ.ស.) ដែលអនុម័ត ដោយអភិបាលនៃគណៈអភិបាលរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬការិយាល័យនៃរដ្ឋបាលលក្រុង ស្រុក ខណ្ឌ និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន(គ.គ.ថ)អនុម័តដោយគណៈគ្រប់គ្រងសាលារៀន | | |
| ១.២ | ភាគរយថ្នាក់រៀនបានបង្កើត និងដំណើរការគណៈកម្មការគ្រប់គ្រងថ្នាក់រៀន (គ.គ.ថ) | | | |
| ១.៣ | ការប្រជុំប្រចាំត្រីមាសឆមាស និងឆ្នាំដែលដឹកនាំដោយ គ.គ.ស តាមផែនការដែលបានគ្រោង | - សាលារៀនមានផែនការប្រជុំប្រចាំត្រីមាសឆមាស និងប្រចាំឆ្នាំ ជាទៀងទាត់<br>- សាលារៀនមានរបាយការណ៍ និងបញ្ជីវត្តមាន<br>- សាលារៀនមានរបាយការណ៍ ភ្ជាប់និងឧបករណ៍ស្វ័យវាយតម្លៃលទ្ធផលការងារ និងរបាយការណ៍ ប្រចាំឆ្នាំ និងត្រូវបានអនុម័តដោយគ.គ.ស<br>- សាលារៀនមានទិន្នន័យតេស្តស្តង់ដាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ប្រកបដោយសុច្ចរិតភាពបានអនុម័តដោយ គ.គ.ស និងបិទផ្សាយជាសាធារណៈ | | |
| **២. ការចូលរួមរបស់សហគមន៍** | | | | |
| ២.១ | សាលារៀនមានកិច្ចសហប្រតិបត្តិការភាពជាដៃគូវិនិយោគជាមួយវិស័យ សាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍ | - សាលារៀនមានរៀបចំផែនការស្តីពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងមានប្លង់មេច្បាស់លាស់<br>- គណៈគ្រប់គ្រងសាលារៀន និង គ.គ.ស. បានពិភាក្សាអំពីការកៀរគរ រកដៃគូវិនិយោគ លើការរៀបចំអាហារដ្ឋាន ទីលានកីឡា សាលប្រជុំ អគារពហុបំណង ការដាក់ឱ្យអនុវត្តកម្មវិធីសិក្សាទំនើបជាដើម<br>- គណៈគ្រប់គ្រងសាលារៀន និង គ.គ.ស. | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | តស្លុតាង | ពិន្ទុ |
| | | ស្វែងរកដៃគូសហប្រតិបត្តិការ និងវិនិយោគ ទៅតាមផែនការមេ និងតម្រូវការ<br>- មានការចុះកិច្ចព្រមព្រៀងដោយឈរលើផលប្រយោជន៍សិស្សជាធំ<br>- សិស្សានុសិស្សបានទទួលផលពីការសហប្រតិបត្តិការ | | |
| ២.២ | ភាគរយសិស្សត្រៀមនឹងបោះបង់ ឬបោះបង់ការសិក្សា បានត្រឡប់មករៀនវិញទៀងទាត់ក្រោមការគាំទ្រពីសហគមន៍ | - សាលារៀនមានរៀបចំប្រជុំណែនាំដល់គ្រូប្រចាំថ្នាក់ អំពីការកំណត់អត្តសញ្ញាណសិស្សត្រៀមបោះបង់ការសិក្សា<br>- គ្រូប្រចាំថ្នាក់រាយការណ៍អំពីស្ថិតិសិស្សត្រៀមបោះបង់ការសិក្សា<br>- នាយកសាលា គ្រូប្រចាំថ្នាក់ និងគ.គ.ស. ប្រជុំពិភាក្សាអំពីការទប់ស្កាត់សិស្សកុំឱ្យបោះបង់ការសិក្សា និងគាំទ្រពួកគេដើម្បីបានមករៀនទៀតទាត់<br>- ផ្ទៀងផ្ទាត់ជាមួយសិស្សម្នាក់ៗតាមរយៈការបញ្ជាក់ពីសិស្សានុសិស្ស និងអ្នកពាក់ព័ន្ធផ្សេងទៀត | | |
| **៣. ការគាំទ្ររបស់សហគមន៍** | | | | |
| ៣.១ | បរិមាណចំណូលមូលនិធិបង់ចូលសាលារៀន | - សាលារៀនមានរៀបចំផែនការអភិវឌ្ឍសាលារៀនទាំង៤<br>- នាយកសាលា និង គ.គ.ស. បង្ហាញអំពីបរិមាណចំណូលចំណាយ ទាំងថវិការដ្ឋ (លើកលែងមូលនិធិដំណើរការសាលារៀនបន្ថែម) និងថវិកាដែលមានមកពីប្រភព ៣ ផ្សេងទៀត ដូចមានចែងក្នុងសៀវភៅ SOF<br>- ប្រៀបធៀបចំណូលថវិការដ្ឋ និងថវិកាពីប្រភពទាំង៣ | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | គស្តុតាង | ពិន្ទុ |
| ស្តង់ដាទី៤៖ ដំណើរការប្រតិបត្តិ និងរដ្ឋបាលសាលារៀន | | | | |
| ១. ការគ្រប់គ្រងរដ្ឋបាលទូទៅ | | | | |
| ១.១ | សាលារៀនមានរចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកភារកិច្ចតាមការណែនាំ | - សាលារៀនមានរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ត្រឹមត្រូវតាមការណែនាំ៖១)រចនាសម្ព័ន្ធ គណៈគ្រប់គ្រងសាលារៀន ២)រចនាសម្ព័ន្ធក្រុមបច្ចេកទេស ៣)រចនាសម្ព័នក្រុមការងារឃុំជេន | | |
| ១.២ | សាលារៀនមានប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ថិតិអប់រំច្បាស់លាស់ (បុគ្គលិក សិស្ស សារពើភណ្ឌ) | - សាលារៀនមានប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ថិតិ បុគ្គលិក អប់រំ និងសិស្សានុសិស្សច្បាស់លាស់<br>- មានប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌ ទ្រព្យសម្បត្តិរដ្ឋច្បាស់លាស់ | | |
| ១.៣ | សាលារៀនមាន App សម្រាប់ប្រព័ន្ធ គ្រប់គ្រងទិន្នន័យសាលារៀន | - សាលារៀនប្រើប្រាស់ App សម្រាប់គ្រប់គ្រងទិន្នន័យសាលារៀន | | |
| ១.៤ | ចំនួនគ្រូលើស គ្រូខ្វះតាមមុខវិជ្ជា | - សាលារៀនមានបញ្ជីឈ្មោះគណៈគ្រប់គ្រង និងគ្រូ បង្រៀនតាមមុខវិជ្ជាឯកទេសនៃភូមិសិក្សាដែលលើស ឬ ខ្វះតាមមុខវិជ្ជា រៀបតាមលំដាប់នៃឆ្នាំសិក្សា | | |
| ២. ការរៀបចំផែនការអភិវឌ្ឍសាលារៀន | | | | |
| ២.១ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ សាលារៀន ៥ឆ្នាំ ផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំ ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ បានរៀបចំតាមការណែនាំ | - សាលារៀនមានចក្ខុវិស័យ បេសកកម្ម យុទ្ធ សាស្ត្រ និងសកម្មភាពគន្លឹះសម្រាប់អនុវត្ត<br>- សាលារៀនមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ៥ឆ្នាំ ផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំ ផែនការថវិកាប្រចាំឆ្នាំ ផ្តោតលើក្រុមគោលដៅ នៃសូចនាករ<br>- សាលារៀនមានផែនការកែលម្អសាលា | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតធៀបធ្លាត់សូចនាករ | កម្រិតធៀបធ្លាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | | រៀនបានអនុម័តជាផ្លូវការដោយ(គ.គ.ស.) និង កា.រិ.នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ | | |
| ៣. ការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក | | | | |
| ៣.១ | ភាគរយគ្រូបង្រៀននិងបុគ្គលិកអប់រំបានចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ | - គ្រូបង្រៀន បុគ្គលិកអប់រំ និងនាយកសាលាបានចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ ដោយមានកំណត់ចំណុចដៅនៃសូចនាករ លទ្ធផលច្បាស់លាស់ផ្តោតលើ៖<br>• លទ្ធផលសិក្សារៀនសូត្ររបស់សិស្សតាមមុខវិជ្ជា<br>• លទ្ធផលសិក្សារៀនសូត្ររបស់សិស្សសមត្ថភាពភាសាខ្មែរ និងគណិតវិទ្យា<br>• ផែនការថ្នាក់រៀន និងផែនការរៀនសូត្រសិស្សប្រចាំឆ្នាំ<br>• ការពិនិត្យតាមដានថ្នាក់រៀន និងការសិក្សាសិស្សម្នាក់ៗ<br>• ការប្រកួតប្រជែងសមត្ថភាពសិស្សអានភាសាខ្មែរ និងគណនាលេខ<br>• ជួយសិស្សមានបញ្ហាសង្គម និងសេដ្ឋកិច្ច<br>- នាយកសាលា និង គ.គ.ស. បានធ្វើការវាយតម្លៃនៃការអនុវត្តកិច្ចព្រមព្រៀងរបស់គ្រូបង្រៀននិងបុគ្គលិកអប់រំ នៅចុងឆ្នាំ ព្រមទាំងមានការផ្តល់ការសរសើរ និងរង្វាន់លើកទឹកចិត្តជាដើម | | |
| ៣.២ | ចំនួននាយកនិងនាយករងបានចុះកិច្ចព្រម | - គណៈគ្រប់គ្រងសាលារៀនអនុវត្តការងារផ្អែកតាមកិច្ចព្រមព្រៀងបានល្អដូចជា៖ | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | ព្រៀង លទ្ធផលការងារប្រចាំឆ្នាំ | • ផលសម្រេចអប់រំរបស់សាលារៀន<br>• លទ្ធផលប្រឡងជាប់សិស្សថ្នាក់ទី៩<br>• ការធ្វើតេស្តស្តង់ដាសិស្សការកត់ត្រា និងការប្រើប្រាស់លទ្ធផលតេស្ត<br>• ផែនការផែនការប្រតិបត្តិប្រចាំឆ្នាំ និងការអនុម័តពីគណៈកម្មការគ្រប់គ្រងសាលារៀន<br>• ការប្រកួតប្រជែងសមត្ថភាពសិស្ស ភាសាខ្មែរ និងគណិតវិទ្យា<br>• ការពិនិត្យតាមដាន ការធ្វើអធិការកិច្ចការបង្រៀន និងការវាយតម្លៃកម្រិតសាលារៀន<br>• ការអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារ និងការប្រកួតប្រជែងសមត្ថភាពសិស្សកម្រិតសាលារៀន<br>• ការកសាង និងរក្សាគណនេយ្យភាពសាលារៀន<br>- គណៈគ្រប់គ្រងដែលសាលារៀនទទួលបានស្វ័យវាយតម្លៃជាសាលារៀនគំរូ នៅដំណាច់ឆ្នាំសិក្សា<br>- សាលារៀនមានរបាយការណ៍ ភ្ជាប់និងឧបករណ៍ស្វ័យវាយតម្លៃលទ្ធផលការងារ | | |
| **៤. វង្វាយតម្លៃលទ្ធផលសិក្សា** | | | | |
| ៤.១ | ការរៀបចំធ្វើតេស្តស្តង់ | - នាយកសាលាបានរៀបចំប្រជុំផ្សព្វផ្សាយ | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | ដា ដើមឆ្នាំឬចុងឆ្នាំ ប្រចាំខែ ត្រីមាស ឆមាស និងតេស្តស្តង់ដាថ្នាក់ទី៨ បានរៀបចំទៀងទាត់ | អំពីគោលការណ៍នៃការរៀបចំនិងអនុវត្តតេស្តស្តង់ដាសម្រាប់ការប្រឡងនានា<br>- គណៈគ្រប់គ្រងសាលារៀបចំយន្តការនៃការធ្វើតេស្តស្តង់ដា ដោយបែងចែកសកម្មភាព មុនពេល អំឡុងពេល និងក្រោយពេលនៃការធ្វើតេស្តស្តង់ដា<br>- គ.គ.ស. គ.គ.ថ. និងមាតាបិតា អ្នកអាណាព្យាបាល ពិនិត្យតាមដាន និងចូលរួមអនុវត្ត តេស្តស្តង់ដា<br>- លទ្ធផលតេស្តស្តង់ដា ត្រូវបានយកទៅប្រើជាមូលដ្ឋានក្នុងការរៀបចំផែនការអភិវឌ្ឍសាលារៀន ផែនការថ្នាក់រៀន និងការចុះកិច្ចព្រមព្រៀងលទ្ធផលរវាងគ្រូបង្រៀនជាមួយនាយក និងគ្រូបង្រៀនជាមួយមាតាបិតា អ្នកអាណាព្យាបាល | | |
| **៥. ការលើកកម្ពស់សុខភាពសិក្សា និងអាហារូបត្ថម្ភរបស់សិស្ស** | | | | |
| ៥.១ | ការលើកកម្ពស់សេវាថែទាំសុខភាពបឋម | - គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា មានសមាសភាព តួនាទីភារកិច្ចច្បាស់លាស់ និងមាននីត្យានុកូល<br>- ភស្តុតាងនៃបរិក្ខានិងសម្ភារៈសង្គ្រោះបឋម<br>- របាយការណ៍ស្តីពីការផ្តល់ថ្នាំបង្ការតាមកម្មវិធីជាតិ ផ្តល់ថ្នាំបង្ការ ឬថ្នាំទម្លាក់ដង្កូវព្រូន<br>- បន្ទប់សុខភាពនិងសម្ភារៈប្រើប្រាស់ជាមូលដ្ឋានចាំបាច់<br>- យន្តការគ្រប់គ្រងកិច្ចដំណើរការបន្ទប់សុខភាព | | |
| ៥.២ | ការពិនិត្យសុខភាពសិស្ស | - ផែនការពិនិត្យសុខភាពសិស្ស និងសៀវភៅតាមដានសុខភាពសិស្ស | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតធ្វៀងផ្ទាត់សូចនាករ | កម្រិតធ្វៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | តស្តុតាង | ពិន្ទុ |
| | | - របាយការណ៍ទិន្នន័យស្តីពីការពិនិត្យសុខភាពសិស្ស ឬការផ្តល់សេវាសុខភាពផ្សេងៗ<br>- របាយការណ៍ស្តីពីកិច្ចអន្តរាគមន៍ចំពោះសិស្សដែលមានបញ្ហាសុខភាពមិនល្អបានទៅទទួលសេវាគាំទ្រ | | |
| ៥.៣ | ការលើកកម្ពស់ទឹកស្អាត និងអនាម័យ | - បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ បណ្តាញទឹកស្អាត<br>- កម្មវិធីការគ្រប់គ្រងអនាម័យពេលមករដូវរបស់កុមារី<br>- បណ្តាញទឹកស្អាតសម្រាប់ទទួលទានរបស់គ្រូ សិស្ស<br>- កាលវិភាគស្តីពីការលាងសម្អាតដៃនិងដុសសម្អាតធ្មេញជាក្រុមសម្រាប់សិស្សទាំងអស់ | | |
| ៥.៤ | ការលើកកម្ពស់សុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុខភាព | - ការបិទផ្សាយគោលការណ៍ណែនាំស្តីពីការលើកកម្ពស់សុវត្ថិភាពចំណីអាហារនិងអាហារប្រកបដោយសុខភាព<br>- អ្នកលក់មានកិច្ចសន្យាច្បាស់លាស់ជាមួយនាយកសាលា ឬអាជ្ញាធរមានសមត្ថកិច្ច<br>- យន្តការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនិងអាហារប្រកបដោយសុខភាព | | |
| ៥.៥ | ការអនុវត្តមុខវិជ្ជាអប់រំសុខភាព | - ផែនការបង្រៀន និងកាលវិភាគបង្រៀនមុខវិជ្ជាអប់រំសុខភាព<br>- សៀវភៅតាមដានការបង្រៀនមុខវិជ្ជាអប់រំសុខភាព<br>- របាយការណ៍ពីការអប់រំផ្សព្វផ្សាយពីសារសុខភាព ផ្សេងៗគ្រប់រូបភាព<br>- កម្មវិធីប្រឡងមុខវិជ្ជាអប់រំសុខភាព និង | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតឆ្លៀងផ្ទាត់សូចនាករ | កម្រិតឆ្លៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | | តារាងសម្រង់ពិន្ទុ មុខវិជ្ជាអប់រំសុខភាពរបស់សិស្ស | | |
| ៥.៦ | ការលើកកម្ពស់បរិស្ថាន ស្អាត បៃតង សុវត្ថិភាព អនាម័យ និងមេត្រីភាព | - ធុងសំរាមបានរៀបចំស្របតាមលក្ខណៈបច្ចេកទេស ឬមានឡដុតសំរាមតាមស្តង់ដាបច្ចេកទេស<br>- សួនផ្កាលម្អ រុក្ខជាតិ ដើមឈើ សួនបន្លែ វិលជុំ សួនជីវៈចម្រុះ<br>- យន្តការត្រួតពិនិត្យនិងការសម្អាតអនាម័យ<br>- សាលារៀនគ្មានប្រើប្រាស់ថង់ប្លាស្ទិក | | |
| ៥.៧ | ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ការការពារ កុមារ ការបង្ការគ្រោះមហន្តរាយនានា | - សាលារៀនមានរបង ទ្វារចេញចូល<br>- សាលារៀនមានប្រព័ន្ធកិច្ចការពារកុមារ ការរៀបចំយន្តការសណ្តាប់ធ្នាប់ រក្សាសុវត្ថិភាព ការដាក់ស្លាកសញ្ញាចរាចរណ៍ ការបង្ការការលង់ទឹក សម្ភារៈបរិក្ខារជូនដំណឹងពីសញ្ញាគ្រោះថ្នាក់ បំពង់ពន្លត់អគ្គីភ័យ | | |
| ៥.៨ | ការអនុវត្តសកម្មភាព អប់រំកាយនិងកីឡា | - ទីធ្លាសម្រាប់ធ្វើសកម្មភាពអប់រំកាយនិងកីឡា<br>- តារាងវាយតម្លៃលទ្ធផលការសិក្សារបស់សិស្សពីមុខវិជ្ជា អប់រំកាយនិងកីឡា | | |
| ៥.៩ | ភាគរយសិស្សខ្សោយស្តាប់ ទទួលបានឧបករណ៍ស្តាប់សម្លេង | - សាលារៀន សហការជាមួយមណ្ឌលសុខភាព ដែលនៅជិតសាលា ពិនិត្យនិងរកសិស្សខ្សោយគំហើញ និងស្តាប់ឱ្យមានទិន្នន័យ ព្រមទាំងមានការចូលរួមគាំទ្រ ពីអ្នកពាក់ព័ន្ធជួយជាសម្ភារៈឬថវិកា | | |
| ៥.១០ | ភាគរយសិស្សខ្សោយគំហើញ ទទួលបានវ៉ែនតាពាក់ | | | |
| **៦. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ** | | | | |
| ៦.១ | សាលារៀនមានបណ្តាញអគ្គិសនី បំពាក់អ៊ីនធើ | - សាលារៀនមានតបណ្តាញអគ្គិសនី<br>- បណ្តាញអគ្គិសនីត្រូវបានតភ្ជាប់ទៅទីចាត់ | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតធៀបផ្ទាត់សូចនាករ | កម្រិតធៀបផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | គស្តុតាង | ពិន្ទុ |
| | ណេត | ការ និងគ្រប់បន្ទប់រៀន និងបន្ទប់ផ្សេងៗទៀត ប្រកបដោយសណ្តាប់ធ្នាប់ និងសុវត្ថិភាព<br>- សាលារៀនមានតបណ្តាញអ៊ីនធើណិត<br>- បណ្តាញអ៊ីនធើណិតត្រូវបានតភ្ជាប់ទៅទីចាត់ការ និងគ្រប់បន្ទប់រៀន និងបន្ទប់ផ្សេងៗទៀត ប្រកបដោយសណ្តាប់ធ្នាប់ និងគុណភាព<br>- សាលារៀនមានបណ្តាញអគ្គីសនី បណ្តាញអ៊ីនធើណិត បន្ទប់ កុំព្យូទ័រ សម្រាប់គាំទ្រដល់ដំណើរការបង្រៀន និងរៀន មានបណ្ណាល័យ សម្រាប់ការសិក្សាស្រាវជ្រាវគ្រូបង្រៀននិងសិស្ស<br>- បន្ទប់រៀនមានបំពាក់ ឧបករណ៍សិក្សាទំនើប ( LCD, Smart TV, Smart board…) | | |
| ៦.២ | សាលារៀនមានបន្ទប់កុំព្យូទ័រសម្រាប់សិស្សរៀន | - សាលារៀនមានអគារ ឬ បន្ទប់សម្រាប់រៀបចំបង្កើតនិងដំណើរការបន្ទប់កុំព្យូទ័រ<br>- សាលារៀនមានបន្ទប់កុំព្យូទ័រ និងកំពុងដំណើរការ<br>- សាលារៀនត្រូវពិភាក្សាគ្នាដើម្បីកៀរគរមូលនិធិពីមាតាបិតា សប្បុរសជនដើម្បីទិញកុំព្យូទ័រ បន្ថែម និងជួលគ្រូបង្រៀនកុំព្យូទ័រស្ម័គ្រចិត្តជាដើម | | |
| ៦.៣ | សាលារៀនមានបណ្ណាល័យ | - សាលារៀនមានសៀវភៅណែនាំប្រតិបត្តិស្តីពី បណ្ណាល័យ<br>- សាលារៀនមានអគារ ឬ បន្ទប់សម្រាប់រៀបចំបង្កើតនិងដំណើរការបណ្ណាល័យ<br>- សាលារៀនមានបណ្ណាល័យតាមស្តង់ដា | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ត្រូវតាម | ពិន្ទុ |
| | | និងកំពុងដំណើរការ<br>- សាលារៀនត្រូវពិភាក្សាគ្នាដើម្បីកៀរគរមូលនិធិពីមាតាបិតា សប្បុរសជន ដើម្បីបំពាក់គ្រឿងសង្ហារឹម ទិញសៀវភៅអានបន្ថែម និងជួល បណ្ណារក្សាស្ម័គ្រចិត្តជាដើម | | |
| ៦.៤ | ភាគរយបន្ទប់រៀនបំពាក់ឧបករណ៍សិក្សាទំនើប (LCD, Smart TV, Smart Board...) | - សាលារៀនមានផែនការបំពាក់ឧបករណ៍សិក្សាទំនើបតាមបន្ទប់រៀន និងការបណ្តុះបណ្តាលគ្រូបង្រៀនឱ្យចេះប្រើប្រាស់<br>- គណៈគ្រប់គ្រងសាលា និង គ.គ.ស. ពិភាក្សាអំពីការស្នើសុំទៅក្រសួង ឬ អង្គការដៃគូអភិវឌ្ឍ ឬ កៀរគរមូលនិធិពីមាតាបិតា សប្បុរសជន ដើម្បីបំពាក់ឧករណ៍សិក្សាទំនើប<br>- គ្រូបង្រៀន ពិភាក្សាជាមួយ គ.គ.ថ. ដើម្បីកៀរគរមូលនិធិដើម្បីបំពាក់ឧករណ៍សិក្សាទំនើប នៅតាមបន្ទប់រៀនរបស់ខ្លួន | | |
| ៦.៥ | សាលារៀនមានទីលានកីឡារួមមាន តារាងបាល់ទះ<br>បាល់ទាត់ បាល់បោះ វាយសី... | - សាលារៀនមានទីតាំងសមស្របសម្រាប់រៀបចំទីលានកីឡា<br>- សាលារៀនមានទីលានលេងកីឡាគ្រប់ប្រភេទនិងកំពុងដំណើរការ<br>- សាលារៀនមានទីលានកីឡាត្រូវពិភាក្សាគ្នាដើម្បីកៀរគរមូលនិធិពីមាតាបិតា សប្បុរសជន ដើម្បីវិនិយោគ និងជួលគ្រូបង្រៀនឯកទេសកីឡាស្ម័គ្រចិត្តជាដើម | | |
| **ស្តង់ដាទី៥៖ គណនេយ្យភាព** | | | | |
| **១. វេទិកាសាធារណៈ** | | | | |
| ១.១ | ការជួបប្រជុំមាតាបិតា | - ចំនួនវេទិកាការជួបជុំមាតាបិតាសិស្សប្រចាំ | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | សិស្ស | - ប្រធានបទៈ ណែនាំអំពីការកាត់បន្ថយនិងលុបបំបាត់ អំពីហិង្សានៅក្នុងគ្រួសារ និងសាលារៀន លទ្ធផលសិក្សានិងជំរុញការសិក្សារៀនសូត្រ ការលើកកម្ពស់ អាហារូបត្ថម្ភគ្រឿងញៀន ច្បាប់ចរាចរណ៍ និងការងារ ផ្សេងៗទៀត<br>- សាលារៀនមានទិន្នន័យពីចំនួនដង ប្រជុំជាមួយ មាតាបិតាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្តោតលើកាត់បន្ថយ និងលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ និងសាលារៀន, លើកកម្ពស់ការសិក្សា ចំណីអាហារ ការអប់រំគ្រឿងញៀន ច្បាប់ចរាចរ<br>- សាលារៀនរៀបចំរបាយការណ៍លទ្ធផលនៃការប្រជុំនិងទិសដៅអនុវត្តបន្ត ភ្ជាប់ជាមួយកំណត់ហេតុប្រជុំ បញ្ជីវត្តមាន តាមប្រធានបទខាងលើ | | |
| **២. ការផ្សាយព័ត៌មានជាសាធារណៈ** | | | | |
| ២.១ | លទ្ធផលតេស្តវាយតម្លៃស្តង់ដានិងព័ត៌មាននានាត្រូវបានអនុម័តដោយ គ.គ.ស. និង/ឬ បិទផ្សាយជាសាធារណៈ | - សាលារៀនមានផែនការសាលារៀន<br>- សាលារៀនមានបិទផ្សាយឯកសារសកម្មភាព ឬស្នាដៃ កុមារ និងព័ត៌មានផ្សេងៗ<br>- សាលារៀនបានផ្តល់របាយការណ៍លទ្ធផលនៃការអភិវឌ្ឍ របស់កុមារឃើត ឱ្យមាតាបិតា អ្នកអាណាព្យាបាល និង សហគមន៍<br>- សាលារៀនមានសកម្មភាពការងាររបស់សាលារៀន<br>- សាលារៀនមានរបាយការណ៍ការងារប្រចាំខែ ប្រចាំ ត្រីមាស ប្រចាំឆមាស និងប្រចាំ | | |

| ល.រ | ស្តង់ដានិងសូចនាករ | កម្រិតធៀបផ្ទាត់សូចនាករ | កម្រិតធៀបផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | កស្តុតាង | ពិន្ទុ |
| | | ឆ្នាំ | | |
| ៣. ការទទួលបានការគាំទ្រពីថ្នាក់ជាតិ | | | | |
| ៣.១ | ចំនួនជងនាយកសាលា និងនាយករងបាន ទទួលការហ្វឹកហាត់អនុវត្តស្តង់ដាសាលារៀនគំរូពីនាយកសាលាផ្សេង ឬពីថ្នាក់លើ | - សាលារៀនមានបញ្ជីរាយនាមនាយក នាយករង ទទួល ការហ្វឹកហាត់ការអនុវត្ត ការគ្រប់គ្រងតាមសាលារៀន /សាលារៀនគំរូ<br>- សាលារៀនមានរបាយការណ៍លទ្ធផលនៃការអនុវត្តជាមួយការិយាល័យអ.យ.កមន្ទីរ អ.យ.ក រាជធានី ខេត្ត ចុះជួយហ្វឹកហាត់ ដោយផ្ទាល់ ឬតាមអនឡាញ | | |
| ៣.២ | ភាគរយគ្រូបង្រៀន បំពេញទស្សនកិច្ចសិក្សាទៅសាលាផ្សេងក្នុងមួយឆ្នាំ | - សាលារៀនមានផែនការទស្សនកិច្ចសិក្សា សម្រាប់គ្រូបង្រៀននិងបុគ្គលិកអប់រំប្រចាំឆ្នាំ<br>- សាលារៀនមានមូលនិធិដើម្បីគាំទ្រដល់ដំណើរទស្សនកិច្ចសិក្សា<br>- សាលារៀនមានរបាយការណ៍ នៃដំណើរទស្សនកិច្ចសិក្សា<br>- សាលារៀនបង្ហាញលទ្ធផលនៃការអនុវត្តដោយយកតាមឧត្តមានុវត្តន៍នៃសាលារៀន ដែលគ្រូបង្រៀននិងបុគ្គលិកអប់រំបានទៅបំពេញទស្សនកិច្ច | | |

តារាងពិន្ទុវាយតម្លៃគ្រឹះស្ថានមធ្យមសិក្សាបឋមទូមិសាធារណៈគំរូ

| ស្តង់ដា | ស្តង់ដាទី១<br>លទ្ធផលសិក្សារបស់សិស្ស | ស្តង់ដាទី២<br>ដំណើរការបង្រៀន និងរៀន | ស្តង់ដាទី៣<br>ការចូលរួមរបស់សហគមន៍ | ស្តង់ដាទី៤<br>ដំណើរការប្រតិបត្តិ និងរដ្ឋបាលសាលារៀន | ស្តង់ដាទី៥<br>គណនេយ្យភាព | សរុប |
|---|---|---|---|---|---|---|
| ចំនួនសូចនាករ | ២០ | ២៩ | ៦ | ២៣ | ៤ | ៨២ |
| ពិន្ទុអតិប្បរមា | ១០០ | ១៤៥ | ៣០ | ១១៥ | ២០ | ៤១០ |
| ពិន្ទុជាប់ស្តង់ដា (៦០%) | ៦០ | ៨៧ | ១៨ | ៦៩ | ១២ | ២៤៦ |

តារាងពិន្ទុវាយតម្លៃគ្រឹះស្ថានមធ្យមសិក្សាទុតិយទូមិសាធារណៈគំរូ

| ស្តង់ដា | ស្តង់ដាទី១<br>លទ្ធផលសិក្សារបស់សិស្ស | ស្តង់ដាទី២<br>ដំណើរការបង្រៀន និងរៀន | ស្តង់ដាទី៣<br>ការចូលរួមរបស់សហគមន៍ | ស្តង់ដាទី៤<br>ដំណើរការប្រតិបត្តិ និងរដ្ឋបាលសាលារៀន | ស្តង់ដាទី៥<br>គណនេយ្យភាព | សរុប |
|---|---|---|---|---|---|---|
| ចំនួនសូចនាករ | ២១ | ២៩ | ៦ | ២៣ | ៤ | ៨៣ |
| ពិន្ទុអតិប្បរមា | ១០៥ | ១៤៥ | ៣០ | ១១៥ | ២០ | ៤១៥ |
| ពិន្ទុជាប់ស្តង់ដា (៦០%) | ៦៣ | ៨៧ | ១៨ | ៦៩ | ១២ | ២៤៩ |

## ៦. គោលការណែនាំស្តង់ដាសាលាមធ្យមសិក្សាគំរូ

### ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស

ស្តង់ដានៃលទ្ធផលសិក្សារបស់សិស្ស គឺជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពរបស់សាលាមធ្យមសិក្សា ដោយផ្តោតលើផលសម្រេចក្នុងឆ្នាំនៃសកម្មភាពចាំបាច់ ដែលសាលារៀនត្រូវផ្តោតការយកចិត្តទុកដាក់

ប្រមូលសិស្សឱ្យបានចូលរៀនតាមផែនការកំណត់ ការធានាឱ្យបានសម្រាប់សិស្សរៀនសូត្របានពេញលេញ ក្នុងនោះសាលារៀនត្រូវកំណត់យកលទ្ធផលសិក្សារបស់សិស្ស ដោយផ្អែកលើការអភិវឌ្ឍផ្នែកទាំង៥របស់សិស្សព្រមទាំងរិះរកវិធានការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ និងការអប់រំសីលធម៌ និងឥរិយាបថរបស់កុមារ។ សាលារៀនផ្តោតការយកចិត្តទុកដាក់ និងកំណត់យកលទ្ធផលសិក្សារបស់សិស្សជាគោលដើម្បីធ្វើការអភិវឌ្ឍសាលារៀន។

**១. ការប្រមូលកុមារចូលរៀន៖** សាលារៀនត្រូវប្រមូលសិស្សចូលរៀនឱ្យបានតាមផែនការ និងចំណុចដៅប្រចាំឆ្នាំ។ ដូច្នេះសាលាត្រូវរៀបចំឱ្យមានដូចខាងក្រោម៖

- **ការចូលរៀនរបស់សិស្ស សាលារៀនត្រូវរៀបចំ៖**
  - រៀបចំបញ្ជីស្ថិតិបញ្ជីសិត្ថិសិស្សដែលត្រូវចូលរៀននៅ ក្នុងភូមិសាស្រ្តសិក្សារបស់ សាលាមធ្យមសិក្សាដោយយោងទៅតាមបញ្ជីឈ្មោះសិស្សពីសាលាបឋមសិក្សា និងអនុវិទ្យាល័យចំណុះ ដែលមានសិស្សត្រូវចូលរៀន
  - រៀបចំ ឬកែសម្រួលផែនទីសិក្សា
  - សំបុត្រកំណើតសិស្ស និងសៀវភៅគ្រួសារសិស្ស

**២. សិស្សរៀនបានគង់វង្សក្នុងសាលារៀន៖** សាលារៀនត្រូវចាត់វិធានការសមស្របដើម្បីធានាឱ្យបានសម្រាប់សិស្សរៀនសូត្របានពេញលេញគ្រប់តាមកម្មវិធីសិក្សាប្រចាំឆ្នាំ។ សាលារៀនត្រូវរៀបចំតាមដានការសិក្សាដោយកត់ត្រាស្រង់ចូលតារាងទិន្នន័យស្ថិតិសិស្សនៅដំណាច់ឆ្នាំសិក្សា និងត្រូវធ្វើផលធៀបទិន្នន័យបវេសនកាល និងដំណាច់ឆ្នាំសិក្សា។

**៣. លទ្ធផលសិក្សារបស់សិស្ស៖** លទ្ធផលសិក្សារបស់សិស្ស គឺការអភិវឌ្ឍនៃផ្នែកទាំង៥ របស់សិស្ស មធ្យមសិក្សាត្រូវយកចិត្តទុកដាក់ពិនិត្យតាមដានការបង្រៀននិងរៀន ដោយរៀបចំផែនការច្បាស់លាស់ក្នុង ការជួយគ្រូបង្រៀន ដើម្បីការប្រែប្រួលការអភិវឌ្ឍរបស់សិស្ស ក្នុងន័យនេះ សាលាត្រូវរិះរកមធ្យាបាយរៀបចំជារបាយការណ៍វាយតម្លៃលទ្ធផលនៃការសិក្សាសិស្សឱ្យបានជាក់លាក់ និងរក្សាទុកដាក់ឱ្យបានត្រឹមត្រូវប្រចាំឆ្នាំសិក្សានីមួយ។ សាលាមធ្យមសិក្សាត្រូវរៀបចំគណនាភាគរយលទ្ធផលសិក្សាប្រចាំឆ្នាំសិក្សារបស់សិស្សផ្តោតលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា និងរក្សាទុកឱ្យបានត្រឹមត្រូវ។

**៤. ស្ថានភាពអាហារូបត្ថម្ភរបស់សិស្ស (ការគាំទ្រផ្នែក សុខភាព និងសុវត្ថិភាពសិក្សា)៖** សាលារៀនត្រូវជំរុញនិងចាត់វិធានការត្រួតពិនិត្យតាមដានជាប្រចាំលើស្ថានភាពអាហារូបត្ថម្ភសិស្ស ដែលកំពុងសិក្សារៀនក្នុងឆ្នាំសិក្សាដើម្បីលើកកម្ពស់សុខុមាលភាពកុមារកាន់តែប្រសើរឡើង។ សាលារៀនត្រូវរៀបចំបញ្ជីកត់ត្រាអំពីស្ថានភាពអាហារូបត្ថម្ភរបស់សិស្សតាមសៀវភៅ សុខភាពសិស្ស (ថ្លឹងទម្ងន់ វាស់កម្ពស់)និងត្រូវរក្សាទុកដាក់ជាឯកសារភស្តុតាងឱ្យត្រឹមត្រូវនៅក្នុងសាលា ដើម្បីបង្ហាញដល់មាតាបិតា ឬអ្នកអាណាព្យាបាលផ្តល់ការកោតសរសើរ ឬផ្តល់បទអន្តរាគមន៍ជួយសិស្សបានទាន់ពេលវេលា។

- **សិស្សមានស្ថានភាពអាហារូបត្ថម្ភធម្មតា សាលារៀនត្រូវរៀបចំ៖**
  - បញ្ជីកត់ត្រាស្ថានភាពអាហារូបត្ថម្ភកុមារ(អាយុ ទម្ងន់ កម្ពស់)
  - សៀវភៅតាមដានសុខភាពកុមារម្នាក់ៗ

- **សិស្សដែលមានបញ្ហាអាហារូបត្ថម្ភទទួលបានកិច្ចអន្តរាគមន៍ សាលារៀនត្រូវរៀបចំ៖**
  - របាយការណ៍ត្រឡប់ពីមាតាបិតាឬអ្នកអាណាព្យាបាល ក្នុងការសហការជួយអន្តរាគមន៍ ឬការនាំកុមារទៅរកសេវាគាំទ្រ
  - របាយការណ៍ពីកិច្ចអន្តរាគមន៍របស់សេវាសុខាភិបាលមូលដ្ឋាន តាមរយៈគណៈកម្មការសុខភាពសិក្សា តាមសាលារៀន
- **សិស្សក្រីក្រ សិស្សជួបការលំបាក ឬគ្រួសារងាយរងគ្រោះ ត្រូវបានជួយគាំទ្រពីកម្មវិធីនានារបស់សាលារៀន សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានបញ្ជី និងទិន្នន័យច្បាស់លាស់ ពីចំនួនសិស្សក្រីក្រ សិស្សជួបការលំបាកយ៉ាប់យ៉ឺន ឬ គ្រួសារងាយរងគ្រោះ បានជួយគាំទ្រពីកម្មវិធីនានា(កម្មវិធីអាហារូករណ៍សិស្សក្រីក្រ) របស់ សាលារៀន និងអាជ្ញាធរដែនដី

៥. **សីលធម៌និងឥរិយាបថរបស់សិស្ស៖** សាលារៀនរៀបចំសកម្មភាពក្នុងអប់រំសីលធម៌ ឥរិយាបថរបស់សមាជិកគ្រួសារសិស្សដើម្បីកាត់បន្ថយហិង្សាក្នុងគ្រួសារឱ្យថយចុះនិងផ្តល់កិច្ចគាំពារនិងអន្តរាគមន៍។ សកម្មភាពចាំបាច់សំខាន់ៗ ដែលសាលារៀនត្រូវរៀបចំនិងអនុវត្តមានដូចខាងក្រោម៖

- **កុមារទទួលបានការប្រឹក្សាយោបល់ សាលារៀនត្រូវរៀបចំ៖**
  - របាយការណ៍អំពីចំនួនករណីហិង្សា ឬ វិបត្តិផ្លូវចិត្តនានា
  - របាយការណ៍អំពីចំនួនកុមារដែលរងហិង្សា ឬ មានវិបត្តិផ្លូវចិត្ត បានទទួលប្រឹក្សាយោបល់
- **ថ្នាក់រៀនដាក់ពិន្ទុ បំណិនសម្បទា និងចរិយាសម្បទាដល់សិស្សប្រចាំឆ្នាំ សាលារៀនត្រូវរៀបចំ៖**
  - របាយការណ៍អំពីចំនួនថ្នាក់រៀនដែលបានដាក់ពិន្ទុបំណិនសម្បទា និងចរិយាសម្បទាដល់សិស្សប្រចាំឆ្នាំ ធៀបជាមួយចំនួនថ្នាក់រៀនសរុប
  - ផ្ទៀងផ្ទាត់ជាមួយបញ្ជីពិន្ទុ សៀវភៅតាមដានការសិក្សា និងសៀវភៅសិក្ខាគារិក

## ស្តង់ដាទី២៖ ការបង្រៀននិងរៀន

ស្តង់ដានៃការបង្រៀននិងរៀនគឺជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពសាលាមធ្យមសិក្សានៃសកម្មភាពចាំបាច់នានាដែលសាលរៀនត្រូវផ្តោតការយកចិត្តទុកដាក់លើការអនុវត្តវិធីសាស្ត្របង្រៀនថ្មីឱ្យបានសមស្រប និងមានប្រសិទ្ធភាព ការអនុវត្តកម្មវិធីសិក្សានិងការរៀបចំផែនការបង្រៀន ការផលិតសម្ភារៈបង្រៀននិងរៀន ការជួយគាំទ្រសិស្ស ការរៀបចំដំណើរការបណ្ណាល័យ ការធ្វើអធិការកិច្ចផ្ទៃក្នុងលើកការបង្រៀននិងរៀន ការប្រជុំបច្ចេកទេស ការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោងសិក្សា និងការអនុវត្តការអប់រំសីលធម៌ ចរិយាធម៌។ ស្តង់ដានៃការបង្រៀននិងរៀន សម្រាប់សាលាមធ្យមសិក្សាគំរូត្រូវបានកំណត់ជាសូចនាករគោលនិងសូចនាកររងដូចខាងក្រោម៖

១. **ការអនុវត្តវិធីសាស្ត្របង្រៀនថ្មី៖** សាលារៀនត្រូវផ្តោតការយកចិត្តទុកដាក់លើដំណើរការបង្រៀននិងរៀន ដោយគ្រូបង្រៀនត្រូវចេះនិងអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ គឺ ការសិក្សាតាមបែបគម្រោង និងការរៀនសម្រប

តាមសមត្ថភាពសិស្សដោយឈរលើវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល ព្រមទាំងដាក់កិច្ចការជាសំណួរ លំហាត់ ឬចំណោទ ឱ្យសិស្សបានអនុវត្ត និងគ្រូបានកែកិច្ចការនិងផ្តល់យោបល់ដល់សិស្ស។ សាលារៀននិងថ្នាក់រៀនត្រូវយកចិត្តដាក់ប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការបង្រៀននិងរៀនឱ្យបានសមស្រប។

- **ការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការបង្រៀននិងរៀន សាលារៀនត្រូវរៀបចំ៖**
  - រៀបចំបន្ទប់កុំព្យូទ័រនិងបណ្ណាល័យ
  - រៀបចំបន្ទប់រៀនបំពាក់ឧបករណ៍សិក្សាទំនើប (LCD, Smart TV, Smart Boad)

**២.ការអនុវត្តកម្មវិធីសិក្សានិងការរៀបចំផែនការបង្រៀន៖** សាលារៀនអនុវត្តកម្មវិធីសិក្សាលម្អិតនិងផែនការបង្រៀន ដោយគ្រូបង្រៀនត្រូវរៀបចំបំណែងចែកកម្មវិធីសិក្សាតាមកម្មវិធីសិក្សាលម្អិតសម្រាប់មធ្យមសិក្សា ផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា និងធ្វើបច្ចុប្បន្នកម្មកិច្ចតែងការបង្រៀន។ សាលារៀន និងថ្នាក់រៀនត្រូវអនុវត្តកម្មវិធីសិក្សាឱ្យបានត្រឹមត្រូវ ជៀសវាងការបាត់ម៉ោងសិក្សា ដោយកំណត់របបប្រជុំវាយតម្លៃការអនុវត្តកម្មវិធីសិក្សាប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ។ សាលារៀននិងថ្នាក់រៀនដំណើរការស្របតាមនិយាមម៉ោងកំណត់ត្រឹមត្រូវ តាមការណែនាំរបស់ក្រសួង ដោយកាត់បន្ថយការបិទទ្វារ សាលារៀនមិនប្រក្រតី អវត្តមានគ្រូ និងអវត្តមានសិស្ស។

- **ថ្នាក់រៀនមានផែនការបង្រៀន៣ឆ្នាំ តាមមុខវិជ្ជា សាលារៀនត្រូវរៀបចំ៖**
  - ថ្នាក់រៀនមានផែនការបង្រៀន៣ឆ្នាំ និង១ឆ្នាំ តាមមុខវិជ្ជា (ប្រធានក្រុមបច្ចេកទេស)
  - បង្រៀនទាន់តាមកម្មវិធី និងផែនការដែលបានគ្រោងទុក
- **ថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា សាលារៀនត្រូវរៀបចំ៖**
  - ថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំ តាមមុខវិជ្ជា និងតាមកម្រិតថ្នាក់ (ប្រធានក្រុមបច្ចេកទេស)
- **ថ្នាក់ដែលមានបំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជា ប្រចាំសប្តាហ៍ ប្រចាំខែ និងឆ្នាំ**
  - សាលារៀនមានតារាងបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំខែនិងសប្តាហ៍ តាមមុខវិជ្ជា និងតាមកម្រិតថ្នាក់
  - សាលារៀនមានផែនការបង្រៀនប្រចាំថ្ងៃ តាមកាលវិភាគប្រចាំ សប្តាហ៍ ផែនការបង្រៀន ៣ខែម្តង
- **ចំនួនមុខវិជ្ជា ដែលគ្រូបង្រៀនតាមមុខវិជ្ជាពីថ្នាក់ទី៧ដល់៩មានកិច្ចតែងការបង្រៀន(មុខវិជ្ជា)**
  - គ្រូតាមមុខវិជ្ជាម្នាក់ៗគ្រប់កម្រិតថ្នាក់ ត្រូវធ្វើកិច្ចតែងការ បង្រៀន/គម្រោងបង្រៀនមួយមេរៀនមានច្រើនម៉ោង (ប្រធានក្រុមបច្ចេកទេស និងនាយករង ទទួលបន្ទុកបច្ចេកទេស)
- **ចំនួនដងគ្រូអវត្តមាននិងមិនមានគ្រូជំនួស សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានបញ្ជីកត់ត្រាចំនួនដងនៃគ្រូម្នាក់ៗនៅពេលអវត្តមាន
  - សាលារៀនមានលិខិតអនុញ្ញាតច្បាប់
- **ចំនួនថ្ងៃសាលាបិទទ្វារមិនតាមការឈប់ ប្រតិទិនសម្រាកប្រចាំឆ្នាំ សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានកំណត់ហេតុឬរបាយការណ៍ពីការផ្អាក ដំណើរការបង្រៀន និងរៀន

o ផ្តល់ព័ត៌មានទៅការិយាល័យអប់រំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅពេលសាលារៀនបិទទ្វារ

- **សិស្សមាននិងអនុវត្តការ តាមដានផែនការសិក្សារៀនសូត្រប្រចាំឆ្នាំសិក្សា សាលារៀនត្រូវរៀបចំ៖**
  - o សិស្សមានផែនការសិក្សារៀនសូត្របីខែ និងមួយឆ្នាំ មានលទ្ធផលតេស្តដើមឆ្នាំ គ្រប់កម្រិតថ្នាក់ តាមមុខវិជ្ជា
  - o ពិនិត្យតាមដានលទ្ធផលសិក្សាប្រចាំខែ ដឹកនាំដោយគ្រូបន្ទុកថ្នាក់។ សម្រាប់ថ្នាក់ទី៧ថ្មី សាលាត្រូវបង្ហាញ ពីលទ្ធផលតេស្តដើមឆ្នាំ លើមុខវិជ្ជាគោលភាសាខ្មែរ និងគណិតវិទ្យា។ (គ្រូបន្ទុកថ្នាក់ និងគណៈគ្រប់គ្រងសាលា)

៣. **សម្ភារៈរៀននិងបង្រៀន៖** សាលារៀននិងថ្នាក់រៀនយកចិត្តទុកដាក់លើដំណើរការបង្រៀននិងរៀនគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់នៅមធ្យមសិក្សា ផលិតសម្ភារៈឧបទេសឱ្យបានគ្រប់គ្រាន់តាមប្រធានបទ។

- **ផលធៀបសិស្ស សៀវភៅសិក្សាគោល សាលារៀនត្រូវរៀបចំ៖**
  - o សាលារៀនមានបញ្ជី និងទិន្នន័យពីចំនួនសិស្ស ដែលមានសៀវភៅសិក្សាគោលតាមការណែនាំ៖ មធ្យមសិក្សាបឋមភូមិ ១/១
  - o ផ្ទៀងផ្ទាត់ជាមួយសិស្សម្នាក់ៗតាមរយៈការបញ្ជាក់ពីសិស្សានុសិស្សនិងអ្នកពាក់ព័ន្ធផ្សេងទៀត
- **ចំនួនថ្នាក់ដែលបានប្រើប្រាស់បន្ទប់កុំព្យូទ័រ សាលារៀនត្រូវរៀបចំ៖**
  - o សាលារៀនមានទិន្ន័យពីចំនួនសិស្សបានចូលប្រើប្រាស់បន្ទប់កុំព្យូទ័រ និងកត់ត្រាបានទៀងទាត់
  - o សាលារៀនមានកាលវិភាគ និងបញ្ជីកត់ត្រាអំពី ដំណើរការបន្ទប់កុំព្យូទ័រ
- **ចំនួនថ្នាក់ដែលបានប្រើប្រាស់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ សាលារៀនត្រូវរៀបចំ៖**
  - o សាលារៀនមានទិន្ន័យចំនួនសិស្សបានចូលប្រើប្រាស់បន្ទប់ពិសោធន៍និងកត់ត្រាបានទៀងទាត់
  - o សាលារៀនមានកាលវិភាគ និងបញ្ជីកត់ត្រាអំពី ដំណើរការបន្ទប់ពិសោធន៍

៤. **ការជួយគាំទ្រសិស្ស៖** សាលារៀនផ្តោតការជួយគាំទ្រកុមារទាំងនៅក្នុងសាលារៀន ថ្នាក់រៀន និងនៅផ្ទះ ដោយគ្រូបង្រៀនត្រូវដាក់ឬបង្កើតកិច្ចការឱ្យកុមារចូលរួមធ្វើសកម្មភាពនៅសាលារៀន ថ្នាក់រៀន និងមានការផ្តល់មូលវិចារណ៍ល្អពីគ្រូបង្រៀន ចំពោះស្នាដៃកុមារដែលបានធ្វើសកម្មភាពនោះ។ សាលារៀន ថ្នាក់រៀនរៀបចំកិច្ចការសម្រាប់សិស្សធ្វើនៅផ្ទះឱ្យបានសមស្រប ដោយមានការចូលរួមជួយពីមាតាបិតា អ្នកអាណាព្យាលកុមារ និងមានការផ្តល់មូលវិចារណ៍ល្អពីគ្រូបង្រៀនគ្រប់កិច្ចទាំងអស់ត្រឡប់ជូនមាតាបិតា អ្នកអាណាព្យាលសិស្ស។

- **ភាគរយគ្រូបានដាក់លំហាត់ ឬ កិច្ចការផ្ទះតាមមុខវិជ្ជាគោល សាលារៀនត្រូវរៀបចំ៖**
  - o សាលារៀនមានបញ្ជី កត់ត្រាទិន្នន័យពីចំនួនសិស្ស បានទទួលលំហាត់ឬកិច្ចការផ្ទះដែលគ្រូបង្រៀន បានដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយផែនការប្រចាំឆ្នាំ
  - o សាលារៀនមានបញ្ជីកត់ត្រាទិន្នន័យពីចំនួនគ្រូបង្រៀនបានកែកិច្ចការសិស្សជាលំហាត់ឬ កិច្ចការផ្ទះ តាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និង វិទ្យាសាស្ត្រ) ធៀបជាមួយផែនការប្រចាំឆ្នាំ
- **ភាគរយថ្នាក់រៀនមានក្លឹបស្វ័យ សិក្សាមានដំណើរការ សាលារៀនត្រូវរៀបចំ៖**

- សាលារៀនមានបញ្ជី ទិន្នន័យពីចំនួនក្លឹបសិក្សា និងមានដំណើការ
- សាលារៀនមានរបាយការណ៍ស្តីពីសិស្សបានធ្វើកិច្ចការជាគម្រោង នៃក្លឹបសិក្សាតាមរយៈការកត់ត្រាសកម្មភាព
- រៀបចំទុកដាក់រូបថតសកម្មភាពក្នុងកុំព្យូទ័រ

- **ភាគរយសិស្សរៀនយឺតមុខវិជ្ជា ភាសាខ្មែរ និងគណិតវិទ្យា សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានបញ្ជី ទិន្នន័យពីចំនួនសិស្សរៀនយឺត មុខវិជ្ជា ភាសាខ្មែរ និងគណិតវិទ្យា
  - សាលារៀនមានកាលវិភាគប្រចាំសប្តាហ៍ សម្រាប់បំប៉នសិស្សរៀនយឺត មុខវិជ្ជា ភាសាខ្មែរ និងគណិតវិទ្យា

**៥. ដំណើរការបណ្ណាល័យ៖** សាលារៀនត្រូវរៀបចំបណ្ណាល័យឱ្យត្រឹមត្រូវនិងដំណើរការជាប្រចាំ ដែលសិស្សអាចអនុវត្តសកម្មភាពបាន។

- **បណ្ណាល័យបានបង្កើត និងមានស្តង់ដា សាលារៀនត្រូវរៀបចំ៖**
  - បណ្ណាល័យ ឬបន្ទប់
  - សៀវភៅសិក្សាគោល សៀវភៅលំហាត់ សៀវភៅអំណានបន្ថែមគ្រប់កម្រិតថ្នាក់រៀន និងសមាមាត្រទៅចំនួនសិស្សនៅក្នុងសាលា
  - បណ្ណារក្ស និងមានកាលវិភាគចូលអានសៀវភៅ
  - ឧបករណ៍ឌីជីថល និងអ៊ីនធើណែត សម្រាប់បម្រើការបង្រៀន និងរៀន និងស្រាវជ្រាវ
- **ភាគរយសិស្សប្រើបណ្ណាល័យ(មានរបាយការណ៍ពិនិត្យតាមដានរាល់ត្រីមាស) សាលារៀនត្រូវរៀបចំ៖**
  - បញ្ជីឈ្មោះចូលប្រើប្រាស់បណ្ណាល័យ
  - បទបញ្ជាផ្ទៃក្នុងបណ្ណាល័យ
  - កាលវិភាគសិស្សចូលអាន
  - បញ្ជីឈ្មោះសៀវភៅ និងសម្ភារៈ
  - គ្រូបង្រៀនដាក់កិច្ចការសិស្សសម្រាប់ស្រាវជ្រាវក្នុងបណ្ណាល័យ

**៦. ការធ្វើអធិការកិច្ចផ្ទៃក្នុង៖** សាលារៀនផ្តោតការយកចិត្តទុកដាក់ការធ្វើអធិការកិច្ចផ្ទៃក្នុងលើការបង្រៀន និងរៀន ដោយរៀបចំផែនការអធិការកិច្ចការបង្រៀននិងការគ្រប់គ្រងថ្នាក់រៀនប្រចាំឆ្នាំសិក្សា។ នាយកសាលារៀន ត្រូវបានចុះសង្កេតការបង្រៀនរបស់គ្រូឆ្លើយតបតាមផែនការ និងធ្វើអធិការកិច្ចផ្ទៃក្នុងយ៉ាងតិច១ដងក្នុង១ឆ្នាំ ដោយរៀបចំរបាយការណ៍អធិការកិច្ចការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀនរបស់គ្រូបង្រៀនឱ្យបានច្បាស់លាស់ផ្តល់ប្រឹក្សាគរុកោសល្យដល់គ្រូបង្រៀន។

- **ចំនួនដងនាយកសាលារៀនចុះធ្វើអធិការកិច្ចថ្នាក់រៀនតាមផែនការ សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានផែនការ និងរបាយការណ៍អធិការកិច្ច សង្កេតការបង្រៀន និង ការគ្រប់គ្រងថ្នាក់រៀនសម្រាប់ឆ្នាំសិក្សា
  - មានសំណើសុំពីគ្រូបង្រៀន ដើម្បីចុះជួយ

- **ភាគរយគ្រូបង្រៀនទទួលបានការផ្តល់ប្រឹក្សាគរុកោសល្យ/អធិការកិច្ចថ្នាក់រៀនតាមផែនការយ៉ាងតិចមួយដងក្នុងមួយឆ្នាំ សាលារៀនត្រូវរៀបចំ៖**
  - គ្រូបង្រៀនទទួលបានការផ្តល់ប្រឹក្សាគរុកោសល្យពីក្រុមបច្ចេកទេសសាលារៀន
  - គ្រូបង្រៀនទទួលបានការធ្វើអធិការកិច្ចផ្ទៃក្នុងយ៉ាងតិច១ដង/១ឆ្នាំ

៧. **ការប្រជុំបច្ចេកទេស៖** សាលារៀននិងថ្នាក់រៀននីមួយៗមានការប្រជុំពិនិត្យតាមដានការរៀនសូត្រទៀងទាត់តាមផែនការកំណត់។ សាលារៀនត្រូវរៀបចំផែនការការប្រជុំប្រចាំខែ ឆ្នាំ ហើយគ្រប់ដំណើរការកិច្ចប្រជុំបច្ចេកទេសត្រូវមានរបៀបវារៈ រៀបចំរបាយការណ៍/កំណត់ហេតុអង្គប្រជុំ ដោយភ្ជាប់ជាមួយបញ្ជីវត្តមានអ្នកចូលរួមប្រជុំ តាមកាលបរិច្ឆេទឱ្យបានជាក់លាក់។

- **ការប្រជុំបច្ចេកទេសបានអនុវត្តទៀងទាត់ តាមផែនការដែលបានគ្រោង សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានផែនការប្រជុំប្រចាំខែ ឆ្នាំ និងការប្រជុំត្រូវមានវត្ថុបំណងច្បាស់លាស់ដើមឆ្នាំដំណាច់ ឆមាសទី១ (ក្រុមមុខវិជ្ជានីមួយៗ ផ្តោតលើថ្នាក់រៀន នៃមុខវិជ្ជា ដែលមានសិស្សធ្លាក់មធ្យមភាគច្រើនជាងគេ ដើម្បីជួយគ្រូនិងសិស្សបានទាន់ពេល)
  - សាលារៀនមានរបាយការណ៍/កំណត់ហេតុប្រជុំ បញ្ជីវត្តមាន

៨. **ការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោងសិក្សា៖** សាលារៀនត្រូវផ្តោតការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោងសិក្សាដោយបង្កើតកម្មវិធីសិក្សាបន្ថែម ដូចជាការរៀនតាមក្លឹមសិក្សា ក្លឹបយុវជន ការងារស្ម័គ្រចិត្ត ការអប់រំខ្ចីជីថលនិងកម្មវិធីផ្សេងៗទៀត។

- **ភាគរយថ្នាក់បានបង្រៀនភាសាបរទេសក្រៅម៉ោងសិក្សាស្របតាមកម្រិតថ្នាក់ សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានផែនសិក្សាការប្រចាំឆ្នាំ លើកម្មវិធីសិក្សា ភាសាបរទេស
  - សាលារៀនមានបញ្ជីឈ្មោះគ្រូ សិស្ស បង្រៀននិងរៀនភាសាបរទេស
- **ភាគរយសិស្សបានរៀនកុំព្យូទ័រ សមស្របតាមកម្រិតថ្នាក់ សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានកាលវិភាគ និងបញ្ជីកត់ត្រាអំពី ដំណើរការបន្ទប់ កុំព្យូទ័រ និងចំនួនសិស្សបានចូលរៀន
- **ភាគរយថ្នាក់បានបង្រៀនបំណិន ជីវិតក្រៅម៉ោងសិក្សា ដើម្បីរកចំណូល សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានកាលវិភាគ និងបញ្ជីកត់ត្រាចំនួន គ្រូបង្រៀន សិស្សបានចូលសិក្សា និងអនុវត្តលើបំណិន កសិកម្ម និងបច្ចេកទេស និងចំនួនគ្រូបង្រៀន សិស្ស ទទួលបានប្រាក់ចំណូលពីការអនុវត្តបំណិន
- **ចំនួនដងប្រកួតប្រជែងការអានអក្សរ /ស្មូត្រ (ពិពណ៌ស្នាដៃសិស្ស) និងចំនួនដងនៃការប្រកួតប្រជែងការធ្វើ លំហាត់ គណិតវិទ្យា (ពិពណ៌ស្នាដៃសិស្ស) សាលារៀនត្រូវរៀបចំ៖**
  - ថ្នាក់រៀននីមួយៗមានបញ្ជីឈ្មោះសិស្ស បានស្ម័យសិក្សា សន្លឹក កិច្ចការទី១ ទី២ ទី៣ មុនពេលរៀន ជាមួយគ្រូ
  - សាលារៀនមានផែនការ និងកម្មវិធីសម្រាប់ប្រកួត ប្រជែងការអានអក្សរ និងធ្វើលំហាត់គណិ

តវិទ្យា ក្នុង កម្រិតថ្នាក់រៀនមួយ ឬរវាងថ្នាក់និងថ្នាក់ ឬរវាងភូមិ សិក្សា និងភូមិសិក្សា

- ○ សាលារៀនមានកម្មវិធីលើកសសើរ និងជូនរង្វាន់ទៅ តាមលទ្ធភាព និងស្ថានភាពនៃសាលារៀន

**៩. ការអនុវត្តការអប់រំសីលធម៌ ចរិយាធម៌៖** សាលារៀនផ្តោតការអនុវត្តលើការអប់រំសីលធម៌ និងចរិយាធម៌ ដោយសាលារៀនត្រូវបង្កើតការអនុវត្តកម្មវិធីការអប់រំសីលធម៌ និងចរិយាធម៌ ដើម្បីជួយគាំទ្រការអប់រំសិស្ស ក្នុងនោះសាលាត្រូវរៀបចំប្រធានបទសិក្សាដែលទាក់ទងការបណ្តុះទម្លាប់សិស្សឱ្យចេះសំពះ ចេះគួរសម ការប្រើពាក្យសំដីសមរម្យជាមួយអ្នកដទៃ។ សាលារៀន និងថ្នាក់រៀន ត្រូវអនុវត្តការអប់រំចិត្តសង្គមសិស្ស ការអប់រំផ្លូវចិត្តមាតាបិតា អ្នកអាណាព្យាបាល តាមកម្មវិធីអប់រំបែបពុទ្ធសាសនា។

- **ចំនួនដងសាលារៀនបានរៀបចំ កម្មវិធីលើកកម្ពស់ចរិយាធម៌ សីលធម៌ សាលារៀនត្រូវរៀបចំ៖**
  - ○ សាលារៀនមានកម្មវិធីអនុវត្តការអប់រំចិត្តសង្គម ដល់ សិស្សនិង កម្មវិធីអប់រំផ្លូវចិត្តមាតាបិតា ឬអ្នកអាណាព្យាបាល
  - ○ សាលារៀនមានរៀបចំកម្មវិធីសមាធិនៅពេលមុនចេញ មកផ្ទះ ឬពេលគោរពទង់ជាតិ
- **ចំនួនដងថ្នាក់នីមួយៗបានអនុវត្តកម្មវិធីហ្វឹកហាត់កីឡា និងសកម្មភាពសិល្បៈ(ចម្រៀង របាំ តន្ត្រី គំនូរ)សាលារៀនត្រូវរៀបចំ៖**
  - ○ សាលារៀនមានផែនការ និងកាលវិភាគសិស្សបាន ចូលរួមកម្មវិធីហ្វឹកហាត់កីឡាតាមមុខសញ្ញាដែលបានរៀបចំ ជាប្រភេទបាល់ទាត់ បាល់បោះ លោតកម្ពស់...និងមានគ្រូបង្រៀនតាមប្រភេទនៃកីឡា
  - ○ សាលារៀនមានកាលវិភាគ កម្មវិធី និងគ្រូបង្រៀនមុខវិជ្ជា សិល្បៈ លើមុខវិជ្ជាចម្រៀង របាំ តន្ត្រី គំនូ
- **ភាគរយសិស្សបានចូលរួមអនុវត្ត សកម្មភាពនានាសម្រាប់អភិវឌ្ឍយុវជន សាលារៀនត្រូវរៀបចំ៖**
  - ○ សាលារៀនរៀបចំ បំផុស និងកត់ត្រាសកម្មភាពនានា សម្រាប់អភិវឌ្ឍយុវជន ដូចជា៖ សង្គ្រានឆ្នាំថ្មី សកម្មភាពសប្បុរសធម៌ក្នុងសហគមន៍ ជួយជនចាស់ជរា គ្រួសារក្រីក្រ...

## ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍

ស្តង់ដានៃការចូលរួមរបស់សហគមន៍ គឺជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពសាលាមធ្យមសិក្សា ដោយផ្តោតលើផលសម្រេចក្នុងឆ្នាំ នៃសកម្មភាពការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ការចូលរួមរបស់សហគមន៍, និងការគាំទ្ររបស់សហគមន៍។

**១. ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន(គ.គ.ស)និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន(គ.គ.ថ)**

សាលារៀនត្រូវបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដោយមានការចូលរួមពីសំណាក់មាតាបិតា និងសហគមន៍។ ប្រសិនបើមាតាបិតាមិនជួយគាំទ្រនោះទេសាលារៀនក៏មិនជោគជ័យដែរ។ កំណែទម្រង់សាលារៀនកន្លងមកបានបង្ហាញថា សាលារៀនជោគជ័យគឺដោយសារមាន

ការចូលរួមពីអាជ្ញាធរមូលដ្ឋាន សហគមន៍ និងមាតាបិតា អាណាព្យាបាល នៅក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនដែលមានដំណើរការ និងមាន របបប្រជុំទៀងទាត់ ព្រមទាំងចូលរួមក្នុងការរៀបចំផែនការកែលម្អសាលារៀន និងមានការប្រជុំទៀងទាត់។ នាយកនិងនាយករងនឹងត្រូវទទួលការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំពីគណៈកម្មការគ្រប់គ្រងសាលារៀន។ សាលារៀនត្រូវរៀបចំការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន៖

- **ចំនួនសមាសភាពគណៈកម្មការគ្រប់គ្រង សាលារៀន (គ.គ.ស) និងបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រង ថ្នាក់រៀន (គ.គ.ថ) សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានសេចក្ដីសម្រេចស្ដីពីការបង្កើតគណៈ កម្មការគ្រប់គ្រងសាលារៀន(គ.គ.ស.) ដែលអនុម័ត ដោយអភិបាលនៃគណៈអភិបាលរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬការិយាល័យនៃរដ្ឋបាលលក្រុង ស្រុក ខណ្ឌ និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន(គ.គ.ថ)អនុម័តដោយគណៈគ្រប់គ្រងសាលារៀន
- **ការប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំដែល ដឹកនាំដោយ គ.គ.ស តាមផែនការដែលបានគ្រោងសាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានផែនការប្រជុំប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំជាទៀងទាត់
  - សាលារៀនមានរបាយការណ៍ និងបញ្ជីវត្តមាន
  - សាលារៀនមានរបាយការណ៍ ភ្ជាប់និងឧបករណ៍ស្វ័យវាយតម្លៃលទ្ធផលការងារ និងរបាយការណ៍ ប្រចាំឆ្នាំ និងត្រូវបានអនុម័តដោយគ.គ.ស
  - សាលារៀនមានទិន្នន័យគេស្តស្តង់ដាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ប្រកបដោយសុច្ចរិតភាពបានអនុម័តដោយ គ.គ.ស និងបិទផ្សាយជាសាធារណៈ

២. **ការចូលរួមរបស់សហគមន៍៖** ព័ត៌មាននានាត្រូវបានអនុម័តដោយ គ.គ.ស. និងបិទផ្សាយជាសាធារណៈ, សហគមន៍បានចូលរួមប្រជុំទៀងទាត់តាមផែនការ, សហគមន៍ចូលរួមរៀបចំបរិស្ថាន បៃតង អនាម័យ អគារសិក្សា បន្ទប់រៀន សង្ហារិម និងបរិក្ខារសិក្សា, សាលារៀនមាន កិច្ចសហប្រតិបត្តិការភាពជាដៃគូវិនិយោគជាមួយវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍ, មាតាបិតាឬអ្នកអាណាព្យាបាលចូលរួមអនុវត្តកម្មវិធីអប់រំទៀងទាត់។

- **សាលារៀនមានកិច្ចសហប្រតិបត្តិការភាពជាដៃគូវិនិយោគជាមួយវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍ សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានរៀបចំផែនការស្តីពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងមានប្លង់មេច្បាស់លាស់
  - គណៈគ្រប់គ្រងសាលារៀន និង គ.គ.ស. បានពិភាក្សាអំពីការកៀរគរ រកដៃគូវិនិយោគ លើការរៀបចំអាហារដ្ឋាន ទីលានកីឡា សាលប្រជុំ អគារពហុបំណង ការដាក់ឱ្យអនុវត្តកម្មវិធីសិក្សាទំនើបជាដើម
- **ភាគរយសិស្សត្រៀមនឹងបោះបង់ ឬបោះបង់ការសិក្សា បានត្រឡប់មករៀនវិញទៀងទាត់ ក្រោមការគាំទ្រពី សហគមន៍ សាលារៀនត្រូវរៀបចំ៖**

- សាលារៀនមានរៀបចំប្រជុំណែនាំដល់គ្រូប្រចាំថ្នាក់ អំពីការកំណត់អត្តសញ្ញាណសិស្សត្រៀមបោះបង់ការសិក្សា
- គ្រូប្រចាំថ្នាក់រាយការណ៍អំពីស្ថិតិសិស្សត្រៀមបោះបង់ការសិក្សា
- នាយកសាលា គ្រូប្រចាំថ្នាក់ និងគ.គ.ស. ប្រជុំពិភាក្សាអំពីការទប់ស្កាត់សិស្សកុំឱ្យបោះបង់ការសិក្សា និងគាំទ្រពួកគេដើម្បីបានមករៀនទៀតទាត់
- ផ្ទៀងផ្ទាត់ជាមួយសិស្សម្នាក់ៗ តាមរយៈការបញ្ជាក់ពីសិស្សានុសិស្ស និងអ្នកពាក់ព័ន្ធផ្សេងទៀត

៣. **ការគាំទ្ររបស់សហគមន៍៖** មាតាបិតា អ្នកអាណាព្យាបាល រដ្ឋបាលឃុំ សង្កាត់ និងសហគមន៍បានចូលរួមជួយគាំទ្រមូលនិធិ និងកិច្ចដំណើរការគ្រប់គ្រងសាលារៀនជាការផ្តល់ធាតុចូលដល់សាលារៀន ការរក្សាមូលដ្ឋានឱ្យនៅតែរឹងមាំដោយក្នុងនោះបានចូលរួមធនធានពីសហគមន៍ដោយស្ម័គ្រចិត្តជាដើមជាជំនួយដល់កុមារឱ្យមានការរីកចម្រើនលើការសិក្សា ៖

- **បរិមាណចំណូលមូលនិធិបង់ចូលសាលារៀន រៀនសាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានរៀបចំផែនការអភិវឌ្ឍសាលារៀនទាំង៤
  - នាយកសាលា និង គ.គ.ស. បង្ហាញអំពី បរិមាណចំណូលចំណាយ ទាំងថវិការដ្ឋ (លើកលែងមូលនិធិដំណើរការសាលារៀនបន្ថែម) និងថវិកាដែលមានមកពីប្រភព ៣ផ្សេងទៀត ដូចមានចែងក្នុងសៀវភៅ SOF
  - ប្រៀបធៀបចំណូលថវិការដ្ឋ និងថវិកាពីប្រភពទាំង៣

## ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន

ស្តង់ដានៃដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន គឺជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពសាលាមធ្យមសិក្សា ដោយផ្តោតលើផលសម្រេចក្នុងឆ្នាំ នៃសកម្មភាពសាលារៀនដែលមានលក្ខណៈល្អប្រសើរជាសាលាមួយដែលមានការរីកចម្រើន មានការអភិវឌ្ឍលើគ្រប់ផ្នែកដោយឆ្លើយតបដល់លទ្ធផលសិក្សារបស់កុមារបានស្របតាមកម្មវិធីសិក្សាបាន គឺអាស្រ័យលើការគ្រប់គ្រងទូទៅនិងរដ្ឋបាល ការរៀបចំផែនការអភិវឌ្ឍសាលារៀន ការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក វង្វាយតម្លៃលទ្ធផលសិក្សា ការលើកកម្ពស់សុខភាពសិក្សា និងអាហារូបត្ថម្ភ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ។

សាលារៀនមានដំណើរការល្អ អាស្រ័យលើការរៀបចំផែនការសកម្មភាពអនុវត្តច្បាស់លាស់ រយៈពេលមធ្យម និងប្រចាំឆ្នាំ ព្រមទាំងផ្តោតលើផលសម្រេចនៃការអប់រំនិងឈរលើមូលដ្ឋាននៃការវាយតម្លៃលទ្ធផលសិក្សារបស់កុមារត្រឹមត្រូវតាមកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា។ លទ្ធផលវាយតម្លៃការសិក្សារបស់កុមារ ត្រូវបានយកមកប្រើប្រាស់ដើម្បីជួយដល់ការសិក្សារៀនសូត្ររបស់សិស្សរៀនយឺត ។ សាលារៀនត្រូវធ្វើអធិការកិច្ចផ្ទៃក្នុងនិងការប្រជុំបច្ចេកទេសជាទៀងទាត់តាមផែនការ គ្រូបង្រៀន និងនាយកសាលាត្រូវបានបញ្ជូនឱ្យចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំ។

សាលារៀន ត្រូវអនុវត្តការងាររដ្ឋបាលដែលមានប្រសិទ្ធភាពដោយត្រូវយកចិត្តទុកដាក់លើការគ្រប់

គ្រង គ្រូបង្រៀន ដូចជាបញ្ហាលើស ខ្វះគ្រូ គ្រូបង្រៀនតាមមុខវិជ្ជា ការរៀបចំផែនការដំណើរការសាលារៀន ការផ្ដល់ សម្ភារៈឧបទេស រួមទាំងវិធីសាស្ត្របង្រៀន។

១. **ការគ្រប់គ្រងទូទៅនិងរដ្ឋបាល ៖** សាលារៀនមានរចនាសម្ព័ន្ធរដ្ឋបាលគ្រប់គ្រងត្រឹមត្រូវ, សាលារៀនមានប្រព័ន្ធគ្រប់គ្រប់ទិន្នន័យស្ថិតិអប់រំច្បាស់លាស់(បុគ្គលិក សិស្ស និងសារពើភណ្ឌ)សាលារៀនប្រើប្រាស់ App សម្រាប់ប្រព័ន្ធ គ្រប់គ្រងទិន្នន័យសាលារៀនដែលមានគ្រូលើស ខ្វះបានថយចុះ ត្រូវបានដោះស្រាយ។

- **សាលារៀនមានរចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកភារកិច្ចតាមការណែនាំ សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ត្រឹមត្រូវតាមការណែនាំ៖១)រចនាសម្ព័ន្ធគណៈគ្រប់គ្រងសាលារៀន ២)រចនាសម្ព័ន្ធក្រុមបច្ចេកទេស ៣)រចនាសម្ព័នក្រុមការងារយុវជន ៤)គុណវុឌ្ឍិកម្រិតបរិញ្ញាបត្រស្របនឹងភូមិសិក្សាឬខ្ពស់ជាង
- **សាលារៀនមានប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ថិតិអប់រំច្បាស់លាស់ (បុគ្គលិក សិស្ស សារពើភណ្ឌ) សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ថិតិបុគ្គលិក អប់រំ និងសិស្សានុសិស្ស ច្បាស់លាស់
  - មានប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌ ទ្រព្យសម្បត្តិរដ្ឋច្បាស់លាស់
- **សាលារៀនមាន App សម្រាប់ប្រព័ន្ធ គ្រប់គ្រងទិន្នន័យសាលារៀន សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនប្រើប្រាស់ App សម្រាប់គ្រប់គ្រងទិន្នន័យ សាលារៀន
- **ចំនួនគ្រូលើស គ្រូខ្វះ តាមមុខវិជ្ជា សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានបញ្ជីឈ្មោះគណៈគ្រប់គ្រង និងគ្រូ បង្រៀនតាមមុខវិជ្ជាឯកទេសនៃភូមិសិក្សាដែលលើស ឬ ខ្វះតាមមុខវិជ្ជា រៀបតាមលំដាប់នៃឆ្នាំសិក្សា

២. **ការរៀបចំផែនការអភិវឌ្ឍសាលារៀន៖** សាលារៀនបានកំណត់ចក្ខុវិស័យ បេសកកម្ម យុទ្ធសាស្ត្រ និង សកម្មភាពគន្លឹះ, សាលារៀនមានរបាយការណ៍ប្រចាំឆ្នាំត្រឹមត្រូវ, ផែនការសាលារៀន(៥ឆ្នាំ ៣ឆ្នាំ និង១ឆ្នាំ) បានរៀបចំតាមការណែនាំ៖

- **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ៥ឆ្នាំ ផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំ ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ បានរៀបចំតាមការណែនាំសាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានចក្ខុវិស័យ បេសកកម្ម យុទ្ធសាស្ត្រ និង សកម្មភាពគន្លឹះ
  - ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ៥ឆ្នាំ
  - ផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំ
  - ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការថវិកាប្រចាំឆ្នាំ
  - ផែនការកែលម្អសាលារៀនបានអនុម័តជាផ្លូវការ

៣. **ការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក៖** សាលារៀនត្រូវផ្ដោតការយកចិត្តទុកដាក់លើការបំពេញការងាររបស់បុគ្គលិកដោយនាយករង និងគ្រូបង្រៀនត្រូវចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំជាមួយនាយកសាលា នាយកសាលាត្រូវចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំជាមួយគណៈគ្រប់គ្រងសាលារៀន។ សាលារៀន ត្រូវធ្វើការតម្លៃការបំពេញការងាររបស់បុគ្គលិក នាយកសាលាត្រូវវាយតម្លៃនាយករង និង

គ្រូបង្រៀន និងមានការឯកភាពពីគណៈកម្មការគ្រប់គ្រងសាលារៀន នាយកសាលារៀនត្រូវវាយតម្លៃការបំពេញការងារដោយគណៈគ្រប់គ្រងសាលារៀន ។

- **ភាគរយគ្រូបង្រៀននិងបុគ្គលិកអប់រំបានចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ សាលារៀនត្រូវរៀបចំ៖**
  - គ្រូបង្រៀន បុគ្គលិកអប់រំ និងនាយកសាលាបានចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ ដោយមានកំណត់ចំណុចដៅនៃសូចនាករលទ្ធផលច្បាស់លាស់ផ្តោតលើ៖
    - លទ្ធផលសិក្សារៀនសូត្ររបស់សិស្សតាមមុខវិជ្ជា
    - លទ្ធផលសិក្សារៀនសូត្ររបស់សិស្សសមត្ថភាពភាសាខ្មែរ និងគណិតវិទ្យា
    - ផែនការថ្នាក់រៀន និងផែនការរៀនសូត្រសិស្សប្រចាំឆ្នាំ
    - ការពិនិត្យតាមដានថ្នាក់រៀន និងការសិក្សាសិស្សម្នាក់ៗ
    - ការប្រកួតប្រជែងសមត្ថភាពសិស្សអានភាសាខ្មែរ និងគណនាលេខ
    - ជួយសិស្សមានបញ្ហាសង្គម និងសេដ្ឋកិច្ច
  - នាយកសាលា និងគ.គ.ស. បានធ្វើការវាយតម្លៃនៃការអនុវត្តកិច្ចព្រមព្រៀងរបស់គ្រូបង្រៀន និងបុគ្គលិកអប់រំ នៅចុងឆ្នាំ ព្រមទាំងមានការផ្តល់ការសរសើរ និងរង្វាន់លើកទឹកចិត្តជាដើម
- **ចំនួននាយកនិងនាយករងបានចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ សាលារៀនត្រូវរៀបចំ៖**
  - គណៈគ្រប់គ្រងសាលារៀនអនុវត្តការងារផ្អែកតាមកិច្ចព្រមព្រៀងបានល្អដូចជា៖
    - ផលសម្រេចអប់រំរបស់សាលារៀន
    - លទ្ធផលប្រឡងជាប់សិស្សថ្នាក់ទី៩
    - ការធ្វើតេស្តស្តង់ដាសិស្ស ការកត់ត្រា និងការប្រើប្រាស់លទ្ធផលតេស្ត
    - ផែនការផែនការប្រតិបត្តិប្រចាំឆ្នាំ និងការអនុម័តពីគណៈកម្មការគ្រប់គ្រងសាលារៀន
    - ការប្រកួតប្រជែងសមត្ថភាពសិស្ស ភាសាខ្មែរ និងគណិតវិទ្យា
    - ការពិនិត្យតាមដាន ការធ្វើអធិការកិច្ចការបង្រៀន និងការវាយតម្លៃកម្រិតសាលារៀន
    - ការអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារ និងការប្រកួតប្រជែងសមត្ថភាពសិស្សកម្រិតសាលារៀន
    - ការកសាង និងរក្សាគណនេយ្យភាពសាលារៀន

**៤. រង្វាយតម្លៃលទ្ធផលសិក្សា៖** សាលារៀនបានរៀបចំការវាយតម្លៃលទ្ធផលសិក្សាសិស្សតាមកម្មវិធី សិក្សាតាមកម្មវិធីសិក្សាលម្អិតសម្រាប់មធ្យមសិក្សា ស្របតាមគោលការណ៍ណែនាំជាធរមាន លទ្ធផលនៃការវាយតម្លៃលទ្ធផលសិក្សារបស់ជាកម្មវត្ថុ នៃការជួយសិស្សរៀនយឺត។

- **ការរៀបចំធ្វើតេស្តស្តង់ដា ដើមឆ្នាំឬចុងឆ្នាំ ប្រចាំខែ ត្រីមាស ឆមាស និងតេស្តស្តង់ដា ថ្នាក់ទី៨ បានរៀបចំទៀងទាត់ សាលារៀនត្រូវរៀបចំ៖**
  - នាយកសាលាបានរៀបចំប្រជុំផ្សព្វផ្សាយអំពីគោលការណ៍នៃការរៀបចំនិងអនុវត្តតេស្តស្តង់ដាសម្រាប់ការប្រឡងនានា

- ○ គណៈគ្រប់គ្រងសាលារៀបចំយន្តការនៃការធ្វើតេស្តស្តង់ដា ដោយបែងចែកសកម្មភាព មុនពេល អំឡុងពេល និងក្រោយពេលនៃការធ្វើតេស្តស្តង់ដា
- ○ គ.គ.ស. គ.គ.ថ. និងមាតាបិតា អ្នកអាណាព្យាបាល ពិនិត្យតាមដាន និងចូលរួមអនុវត្តតេស្តស្តង់ដា
- ○ លទ្ធផលតេស្តស្តង់ដាត្រូវបានយកទៅប្រើជាមូលដ្ឋានក្នុងការរៀបចំផែនការអភិវឌ្ឍសាលារៀន ផែនការថ្នាក់រៀន និងការចុះកិច្ចព្រមព្រៀងលទ្ធផលរវាងគ្រូបង្រៀនជាមួយនាយក និងគ្រូបង្រៀនជាមួយមាតាបិតា អ្នកអាណាព្យាបាល

**៥. ការលើកកម្ពស់សុខភាពសិក្សានិងអាហារូបត្ថម្ភរបស់សិស្ស៖** សាលារៀនផ្តោតការយកចិត្តទុកដាក់អនុវត្តសកម្មភាពការលើកកម្ពស់សុខភាពសិក្សានិងអាហារូបត្ថម្ភរបស់កុមារដោយសាលារៀនត្រូវណែនាំគ្រូបង្រៀនពីសេវាថែទាំសុខភាពបឋម ជំរុញសកម្មភាពពិនិត្យសុខភាពសិស្សឱ្យបានទៀងទាត់ ពង្រឹងការលើកកម្ពស់ទឹកស្អាត ការអនុវត្តអនាម័យជាប្រចាំ និងសុវត្ថិភាពចំណីអាហារប្រកបដោយសុខភាព។ សាលារៀនត្រូវអនុវត្តកម្មវិធីអប់រំសុខភាព រក្សាបរិស្ថានក្នុង និងក្រៅថ្នាក់រៀនឱ្យស្អាត មានសោភ័ណ្ឌភាពបៃតងជានិច្ចប្រកប ដោយមេត្រីភាព ធានានិងរក្សាបានសន្តិសុខសណ្តាប់ធ្នាប់ ព្រមផ្តល់ការការពារកុមារឱ្យរួចផុតពីគ្រោះមហន្តរាយនានា និងបង្កលក្ខណៈសម្បត្តិសមស្របក្នុងការផ្តល់ឱកាសដល់កុមារបានចូលរួមអនុវត្តសកម្មភាពអប់រំកាយ និងកីឡាសម្រាប់សិស្សមធ្យមសិក្សា។

- **ការលើកកម្ពស់សេវាថែទាំសុខភាពបឋម សាលារៀនត្រូវរៀបចំ៖**
  - ○ គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា មានសមាសភាព តួនាទីភារកិច្ចច្បាស់លាស់ និងមាននីត្យានុកូល
  - ○ ភស្តុតាងនៃបរិក្ខារនិងសម្ភារៈសង្គ្រោះបឋម
  - ○ របាយការណ៍ស្តីពីការផ្តល់ថ្នាំបង្ការតាមកម្មវិធីជាតិ ផ្តល់ថ្នាំបង្ការ ឬថ្នាំទម្លាក់ជង្គូវព្រូន
  - ○ បន្ទប់សុខភាពនិងសម្ភារៈប្រើប្រាស់ជាមូលដ្ឋាន ចាំបាច់
  - ○ យន្តការគ្រប់គ្រងកិច្ចដំណើរការបន្ទប់សុខភាព
- **ការពិនិត្យសុខភាពសិស្ស សាលារៀនត្រូវរៀបចំ៖**
  - ○ ផែនការពិនិត្យសុខភាពសិស្ស និងសៀវភៅតាមដានសុខភាពសិស្ស
  - ○ របាយការណ៍ទិន្នន័យស្តីពីការពិនិត្យសុខភាពសិស្ស ឬការផ្តល់សេវាសុខភាពផ្សេងៗ
  - ○ របាយការណ៍ស្តីពីកិច្ចអន្តរាគមន៍ចំពោះសិស្សដែល មានបញ្ហាសុខភាពមិនល្អបានទៅទទួលសេវាគាំទ្រ
- **ការលើកកម្ពស់ទឹកស្អាតនិងអនាម័យ សាលារៀនត្រូវរៀបចំ៖**
  - ○ បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ បណ្តាញទឹកស្អាត
  - ○ កម្មវិធីការគ្រប់គ្រងអនាម័យពេលមករដូវរបស់កុមារី
  - ○ បណ្តាញទឹកស្អាតសម្រាប់ទទួលទានរបស់គ្រូ សិស្ស
  - ○ កាលវិភាគស្តីពីការលាងសម្អាតដៃនិងដុសសម្អាតធ្មេញជាក្រុមសម្រាប់សិស្សទាំងអស់

- **ការលើកកម្ពស់សុវត្ថិភាពចំណី អាហារ និងអាហារប្រកបដោយសុខភាព សាលារៀនត្រូវរៀបចំ៖**
    - ការបិទផ្សាយគោលការណ៍ណែនាំស្ដីពីការលើកកម្ពស់ សុវត្ថិភាពចំណីអាហារនិងអាហារប្រកបដោយសុខភាព
    - អ្នកលក់មានកិច្ចសន្យាច្បាស់លាស់ជាមួយនាយកសាលា ឬអាជ្ញាធរមានសមត្ថកិច្ច
    - យន្តការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនិងអាហារ ប្រកបដោយសុខភាព
- **ការអនុវត្តមុខវិជ្ជាអប់រំសុខភាព សាលារៀនត្រូវរៀបចំ៖**
    - ផែនការបង្រៀន និងកាលវិភាគបង្រៀនមុខវិជ្ជាអប់រំសុខភាព
    - សៀវភៅតាមដានការបង្រៀនមុខវិជ្ជាអប់រំសុខភាព
    - របាយការណ៍ពីការអប់រំផ្សព្វផ្សាយពីសារសុខភាព ផ្សេងៗគ្រប់រូបភាព
    - កម្មវិធីប្រឡងមុខវិជ្ជាអប់រំសុខភាព និងតារាងសម្រង់ពិន្ទុ មុខវិជ្ជាអប់រំសុខភាពរបស់សិស្ស
- **ការលើកកម្ពស់បរិស្ថានស្អាត បៃតង សុវត្ថិភាព អនាម័យ និងមេត្រីភាព សាលារៀនត្រូវរៀបចំ៖**
    - ធុងសំរាមបានរៀបចំស្របតាមលក្ខណៈបច្ចេកទេស ឬមានឡដុតសំរាមតាមស្តង់ដាបច្ចេកទេស
    - សួនផ្កាលម្អ រុក្ខជាតិ ដើមឈើ សួនបន្លែរិលជុំ សួនជីវៈចម្រុះ
    - យន្តការត្រួតពិនិត្យនិងការសម្អាតអនាម័យ
    - សាលារៀនគ្មានប្រើប្រាស់ថង់ប្លាស្ទិក
- **ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ការការពារ កុមារ ការបង្ការគ្រោះមហន្តរាយនានា សាលារៀនត្រូវរៀបចំ៖**
    - សាលារៀនមានរបង ទ្វារចេញចូល
    - សាលារៀនមានប្រព័ន្ធកិច្ចការពារកុមារ ការរៀបចំយន្តការសណ្តាប់ធ្នាប់ រក្សាសុវត្ថិភាព ការដាក់ស្លាកសញ្ញាចរាចរណ៍ ការបង្ការការលង់ទឹក សម្ភារៈបរិក្ខារជូនដំណឹងពីសញ្ញាគ្រោះថ្នាក់ បំពង់ពន្លត់អគ្គីភ័យ
- **ការអនុវត្តសកម្មភាពអប់រំកាយនិងកីឡា សាលារៀនត្រូវរៀបចំ៖**
    - ទីធ្លាសម្រាប់ធ្វើសកម្មភាពអប់រំកាយនិងកីឡា
    - តារាងវាយតម្លៃលទ្ធផលការសិក្សារបស់សិស្សពីមុខវិជ្ជា អប់រំកាយនិងកីឡា
- **ភាគរយសិស្សខ្សោយស្ដាប់ ទទួលបានឧបករណ៍ស្ដាប់សម្លេង និងភាគរយសិស្សខ្សោយគំហើញទទួលបានវ៉ែនតាពាក់ សាលារៀនត្រូវរៀបចំ៖**
    - សាលារៀនសហការជាមួយមណ្ឌលសុខភាព ដែលនៅជិតសាលា ពិនិត្យនិងរកសិស្សខ្សោយគំហើញ និងស្ដាប់ឱ្យមានទិន្នន័យ ព្រមទាំងមានការចូលរួមគាំទ្រ ពីអ្នកពាក់ព័ន្ធជួយជាសម្ភារៈ ឬថវិកា

៦. **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ៖** សាលារៀនផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំដោយសាលារៀនត្រូវរៀបចំបណ្តាញអគ្គិសនី បំពាក់អ៊ីនធើណេត បន្ទប់កុំព្យូទ័រសម្រាប់សិស្សរៀន បណ្ណាល័យ

បន្ទប់រៀនបំពាក់ឧបករណ៍សិក្សាទំនើប (LCD, Smart TV, Smart Board...) និងមានសុវត្ថិភាព ដើម្បីគុណភាព និងប្រសិទ្ធភាពនៃការបង្រៀននិងរៀន។

- **សាលារៀនមានបណ្ដាញអគ្គិសនី បំពាក់អ៊ីនធើណេត សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានតបណ្ដាញអគ្គិសនី
  - បណ្ដាញអគ្គិសនីត្រូវបានតភ្ជាប់ទៅទីចាត់ការ និងគ្រប់បន្ទប់រៀន និងបន្ទប់ផ្សេងៗទៀត ប្រកបដោយសណ្ដាប់ធ្នាប់ និងសុវត្ថិភាព
  - សាលារៀនមានតបណ្ដាញអ៊ីនធើណិត
  - បណ្ដាញអ៊ីនធើណិតត្រូវបានតភ្ជាប់ទៅទីចាត់ការ និងគ្រប់បន្ទប់រៀន និងបន្ទប់ផ្សេងៗទៀត ប្រកប ដោយសណ្ដាប់ធ្នាប់ និងគុណភាព
  - សាលារៀនមានបណ្ដាញអគ្គីសនី បណ្ដាញអ៊ីនធើណិត បន្ទប់ កុំព្យូទ័រ សម្រាប់គាំទ្រដល់ដំណើរការបង្រៀន និងរៀន មានបណ្ណាល័យ សម្រាប់ការសិក្សាស្រាវជ្រាវគ្រូបង្រៀននិងសិស្ស
  - បន្ទប់រៀនមានបំពាក់ ឧបករណ៍សិក្សាទំនើប (LCD, Smart TV, Smart board...)
- **សាលារៀនមានបន្ទប់កុំព្យូទ័រសម្រាប់សិស្សរៀន សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានអគារ ឬបន្ទប់សម្រាប់រៀបចំបង្កើតនិងដំណើរការបន្ទប់កុំព្យូទ័រ
  - សាលារៀនមានបន្ទប់កុំព្យូទ័រ និងកំពុងដំណើរការ
  - សាលារៀនត្រូវពិភាក្សាគ្នាដើម្បីកៀរគរមូលនិធិពីមាតាបិតា សប្បុរសជន ដើម្បីទិញកុំព្យូទ័របន្ថែម និងជួលគ្រូបង្រៀនកុំព្យូទ័រស្ម័គ្រចិត្តជាដើម
- **សាលារៀនមានបណ្ណាល័យ សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានសៀវភៅណែនាំប្រតិបត្តិស្ដីពីបណ្ណាល័យ
  - សាលារៀនមានអគារ ឬ បន្ទប់សម្រាប់រៀបចំបង្កើតនិងដំណើរការបណ្ណាល័យ
  - សាលារៀនមានបណ្ណាល័យតាមស្តង់ដា និងកំពុងដំណើរការ
  - សាលារៀនត្រូវពិភាក្សាគ្នាដើម្បីកៀរគរមូលនិធិពីមាតាបិតា សប្បុរសជន ដើម្បីបំពាក់គ្រឿងសង្ហារឹម ទិញសៀវភៅអានបន្ថែម និងជួលបណ្ណារក្សាស្ម័គ្រចិត្តជាដើម
- **ភាគរយបន្ទប់រៀនបំពាក់ឧបករណ៍សិក្សាទំនើប (LCD, Smart TV, Smart Board...) សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានផែនការបំពាក់ឧបករណ៍សិក្សាទំនើបតាមបន្ទប់រៀន និងការបណ្ដុះបណ្ដាលគ្រូបង្រៀនឱ្យចេះប្រើប្រាស់
  - គណៈគ្រងសាលា និង គ.គ.ស. ពិភាក្សាអំពីការស្នើសុំទៅក្រសួង ឬ អង្គការដៃគូអភិវឌ្ឍ ឬ កៀរគរមូលនិធិពីមាតាបិតា សប្បុរសជន ដើម្បីបំពាក់ឧករណ៍សិក្សាទំនើប
  - គ្រូបង្រៀន ពិភាក្សាជាមួយ គ.គ.ថ. ដើម្បីកៀរគរមូលនិធិដើម្បីបំពាក់ឧករណ៍សិក្សាទំនើប នៅតាមបន្ទប់រៀនរបស់ខ្លួន
- **សាលារៀនមានទីលានកីឡារួមមាន តារាងបាល់ទះ បាល់ទាត់ បាល់បោះ វាយសី... សាលារៀន**

**ត្រូវរៀបចំ៖**

- ○ សាលារៀនមានទីតាំងសមស្របសម្រាប់រៀបចំទីលានកីឡា
- ○ សាលារៀនមានទីលានលេងកីឡាគ្រប់ប្រភេទនិងកំពុងដំណើរការ
- ○ សាលារៀនមានទីលានកីឡាត្រូវពិភាក្សាគ្នាដើម្បីកៀរគរមូលនិធិពីមាតាបិតា សប្បុរសជនដើម្បីវិនិយោគ និងជួលគ្រូបង្រៀនឯកទេសកីឡាស្ម័គ្រចិត្តជាដើម

## ស្តង់ដាទី៥ ៖ គណនេយ្យភាព

ស្តង់ដានៃគណនេយ្យភាពរបស់សាលារៀន គឺជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពសាលាមធ្យមសិក្សា ដោយផ្តោតលើផលសម្រេចក្នុងឆ្នាំ ដោយឆ្លុះបញ្ចាំងពីសកម្មភាពក្នុងការរៀបចំវេទិកាសាធារណៈជាមួយមាតាបិតា ឬអ្នកអាណាព្យាបាល ដើម្បីផ្សព្វផ្សាយព័ត៌មានសមិទ្ធផល និងបញ្ហាប្រឈមទាំងឡាយរបស់សាលាសំដៅស្វែងរកដំណោះស្រាយ ព្រមទាំងការគាំទ្រលើផ្នែកបច្ចេកទេស និងធនធានសម្ភារៈពីគ្រប់ភាគីពាក់ព័ន្ធ។

ក្នុងការរក្សាបាននូវគណនេយ្យភាពសាលារៀនត្រូវកំណត់គោលដៅ សូចនាករផលសម្រេចដែលអាចវាស់វែង និងកំណត់វិធានការដោះស្រាយប្រសិនបើមិនសម្រេចបានតាមសូចនាករ។ របាយការណ៍គឺជាផ្នែកមួយដែលសាលារៀនត្រូវមាន និងផ្សព្វផ្សាយជាសាធារណៈឱ្យបានទៀងទាត់ ដើម្បីបង្កើនភាពជឿទុកចិត្តពីមាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍។ នាយកសាលា ត្រូវពង្រឹងការបំពេញការងាររបស់គ្រូបង្រៀនឱ្យគោរពតាមក្រមសីលធម៌វិជ្ជាជីវៈបង្រៀនគ្រូ អនុវត្តការបង្រៀនឱ្យបានទៀងទាត់គ្រប់ម៉ោងតាមកម្មវិធីសិក្សាកំណត់។ នាយកសាលាត្រូវផ្តល់ឱកាសដល់គ្រូបង្រៀនក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំ ជំរុញលើកទឹកចិត្តគ្រូបង្រៀនឱ្យចូលសកម្មភាពជាមួយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការចុះពិនិត្យសាលារៀនដើម្បីទទួលការគាំទ្រ និងផ្តល់ការហ្វឹកហាត់បច្ចេកទេសថ្មីបន្ថែម។

១. **វេទិកាសាធារណៈ៖** សាលារៀនផ្តោតជាសំខាន់លើការរៀបចំវេទិកាសាធារណៈ ដោយសាលារៀនត្រូវបង្កើតកម្មវិធីជួបប្រជុំមាតាបិតា ឬអ្នកអាណាព្យាបាល(ទៅតាមប្រធានបទ ដូចជាការណែនាំអំពីការកាត់បន្ថយ និងលុបបំបាត់អំពីហិង្សនៅក្នុងគ្រួសារនិងសាលារៀន, ការជំរុញការសិក្សារៀនសូត្រ, ការលើកកម្ពស់អាហារូបត្ថម្ភ, ការអប់រំអំពីគ្រឿងញៀន ច្បាប់ចរាចរ និងការងារផ្សេងៗទៀត)។

- **ការជួបប្រជុំមាតាបិតាសិស្ស សាលារៀនត្រូវរៀបចំ៖**
  - ○ ចំនួនវេទិការជួបជុំមាតាបិតាសិស្សប្រចាំ
  - ○ ប្រធានបទ៖ ណែនាំអំពីការកាត់បន្ថយនិងលុបបំបាត់ អំពីហិង្សានៅក្នុងគ្រួសារ និង សាលារៀន, លទ្ធផលសិក្សានិងជំរុញការ សិក្សារៀនសូត្រ, ការលើកកម្ពស់ អាហារូបត្ថម្ភ, គ្រឿងញៀន, ច្បាប់ចរាចរណ៍ និងការងារផ្សេងៗទៀត
  - ○ សាលារៀនមានទិន្នន័យពីចំនួនដង ប្រជុំជាមួយ មាតាបិតាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្តោតលើកាត់បន្ថយ និងលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ និងសាលារៀន, លើកកម្ពស់ការសិក្សា ចំណីអាហារ ការអប់រំគ្រឿងញៀន ច្បាប់ចរាចរ
  - ○ សាលារៀនរៀបចំរបាយការណ៍លទ្ធផលនៃការប្រជុំនិងទិសដៅអនុវត្តបន្ត ភ្ជាប់ជាមួយ

កំណត់ហេតុប្រជុំ បញ្ជីវត្តមាន តាមប្រធានបទខាងលើ

២. **ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ៖** សាលារៀនផ្តោតការយកចិត្តទុកដាក់ផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ដោយការបង្ហាញលទ្ធផលសិក្សារបស់សិស្ស ផ្សព្វផ្សាយសកម្មភាពប្រតិបត្តិនិងសមិទ្ធផលជាសាធារណៈ, ទិន្នន័យវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ដែលត្រូវបានអនុម័តនិងបិទផ្សាយ។

- **លទ្ធផលតេស្តវាយតម្លៃស្តង់ដានិងព័ត៌មាននានាត្រូវបានអនុម័តដោយ គ.គ.ស. និង/ឬ បិទផ្សាយជាសាធារណៈសាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានផែនការសាលារៀន
  - សាលារៀនមានបិទផ្សាយឯកសារសកម្មភាព ឬស្នាដៃ កុមារ និងព័ត៌មានផ្សេងៗ
  - សាលារៀនបានផ្តល់របាយការណ៍លទ្ធផលនៃការអភិវឌ្ឍ របស់កុមារយើត ឱ្យមាតាបិតា អ្នកអាណាព្យាបាល និង សហគមន៍
  - សាលារៀនមានសកម្មភាពការងាររបស់សាលារៀន
  - សាលារៀនមានរបាយការណ៍ការងារប្រចាំខែ ប្រចាំ ត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ

៣. **ការទទួលបានការគាំទ្រពីថ្នាក់ជាតិ៖** សាលារៀនត្រូវការការគាំទ្រពីថ្នាក់ជាតិ ដោយគណៈគ្រប់គ្រងសាលា ត្រូវបានទទួលការហ្វឹកហាត់អនុវត្តការគ្រប់គ្រងតាមសាលារៀន គ្រូបង្រៀនបានទទួលការបំប៉នសមត្ថភាពលើវិធីសាស្ត្របង្រៀន តាមរយៈក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចុះពិនិត្យតាមដាននិងផ្តល់ការគាំទ្រតាមផែនការ។ គណៈគ្រប់គ្រងសាលាបានទទួលការហ្វឹកហាត់អនុវត្តកម្មវិធីសាលារៀនគំរូ សាលារៀនទទួលការចុះជួយបច្ចេកទេសពីថ្នាក់ក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡា។

- **ចំនួនជងនាយកសាលានិងនាយករងបាន ទទួលការហ្វឹកហាត់អនុវត្តស្តង់ដាសាលារៀនគំរូ ពីនាយកសាលាផ្សេង ឬ ពីថ្នាក់លើសាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានបញ្ជីរាយនាមនាយក នាយករង ទទួល ការហ្វឹកហាត់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន/សាលារៀនគំរូ
  - សាលារៀនមានរបាយការណ៍លទ្ធផលនៃការអនុវត្តជាមួយការិយាល័យអ.យ.ក មន្ទីរអ.យ.ក រាជធានី ខេត្ត ចុះជួយហ្វឹកហាត់ដោយផ្ទាល់ ឬតាមអនឡាញ
- **ភាគរយគ្រូបង្រៀន បំពេញទស្សនកិច្ចសិក្សាទៅសាលាផ្សេងក្នុងមួយឆ្នាំ សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានផែនការទស្សនកិច្ចសិក្សាសម្រាប់គ្រូបង្រៀននិងបុគ្គលិកអប់រំប្រចាំឆ្នាំ
  - សាលារៀនមានមូលនិធិដើម្បីគាំទ្រដល់ដំណើរទស្សនកិច្ចសិក្សា
  - សាលារៀនមានរបាយការណ៍ នៃដំណើរទស្សនកិច្ចសិក្សា
  - សាលារៀនបង្ហាញលទ្ធផលនៃការអនុវត្ត ដោយយកតាមឧត្តមានុវត្តន៍នៃសាលារៀនដែលគ្រូបង្រៀននិងបុគ្គលិកអប់រំបានទៅបំពេញទស្សនកិច្ច

## ៧. ការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ

## ៧.១. ឧបករណ៍វាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ

ស្តង់ដាសាលាមធ្យមសិក្សាគំរូ នឹងត្រូវបានប្រែក្លាយជាឧបករណ៍សម្រាប់វាយតម្លៃសាលាមធ្យមសិក្សា ដែលមានភាគីពាក់ព័ន្ធ ដូចជាការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ព្រមទាំងគ្រប់ភាគីពាក់ព័ន្ធ អាចយកទៅប្រើប្រាស់ក្នុងការវាយតម្លៃ ដើម្បីជាប្រយោជន៍ក្នុងការអភិវឌ្ឍស្តង់ដាសាលាមធ្យមសិក្សាគំរូ។ ឧបករណ៍វាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូជាឧបសម្ព័ន្ធនៃឯកសារនេះ។

*ស្តង់ដាសាលាមធ្យមសិក្សាគំរូ មិនសំដៅទៅរកការដាក់វិន័យ ឬទណ្ឌកម្ម ចំពោះនាយក គ្រូបង្រៀន សិស្ស សហគមន៍ ឬអ្នកពាក់ព័ន្ធដែលបំពេញការងារមិនបានទាន់ឆ្លើយតបស្តង់ដាទេ។ ប៉ុន្តែស្តង់ដាសាលាមធ្យមសិក្សាគំរូជាផ្លាស់ ឬមគ្គុទេសក៍ដឹកនាំអ្នកពាក់ព័ន្ធនានាឈានទៅដល់ ឬ លើសស្តង់ដា។ ប្រសិនបើមានស្តង់ដាណាមួយពុំទាន់សម្រេចនោះអ្នកពាក់ព័ន្ធមាន ឱកាសវាយតម្លៃស្ថានភាព និងកសាងមធ្យោបាយ ដើម្បីធ្វើឱ្យសម្រេច ឬលើសកម្រិតស្តង់ដានាពេលអនាគត។*

*"ស្តង់ដាសាលាមធ្យមសិក្សាគំរូ និងការវាយតម្លៃ ជាមធ្យោបាយ រីឯសាលាមធ្យមសិក្សាជាគោលដៅក្នុងការកែលម្អ"។*

## ៧.២. របៀបនៃការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ

ការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូមានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ លទ្ធផលអាចទទួលយកបានគួរអនុវត្តដូចខាងក្រោម៖

គណៈគ្រប់គ្រងសាលាមធ្យមសិក្សា ត្រូវធ្វើស្វ័យវាយតម្លៃជារៀយៗក្នុងពេលដំណើរការបំពេញការងារតាមរយៈការអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ឬតាមប្រព័ន្ធផ្សេងទៀត តាមស្ថានភាពជាក់ស្តែងរបស់សាលារៀននីមួយៗ ដោយមានការជួយសម្របសម្រួលការងារបច្ចេកទេសពីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការបូកសរុបលទ្ធផល និងវាយតម្លៃសាលាមធ្យមសិក្សា ដើម្បីបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា នៃរដ្ឋបាលរាជធានី ខេត្ត។

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវត្រួតពិនិត្យលើការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូដើម្បីបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា(នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ)។ នាយកដ្ឋាន

មធ្យមសិក្សាចំណោះទូទៅ ដែលជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំវាយតម្លៃពិនិត្យ និងវាយតម្លៃសាលាមធ្យមសិក្សា តាមយន្តការនិងនីតិវិធីជាធរមាន។

ចំពោះបែបបទនិងនីតិវិធីនៃការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ នឹងមានសេចក្តីអធិប្បាយក្នុងចំណុចខាងក្រោមនៃឯកសារនេះ។ ក្របខណ្ឌពេលវេលានៃដំណើរការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូប្រចាំឆ្នាំ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាតាមជាក់ស្តែង។

### ៧.៣. គំរូនៃការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ

ដើម្បីមានមូលដ្ឋានក្នុងការអនុវត្តការវាយតម្លៃសាលាមធ្យមសិក្សា អាចប្រព្រឹត្តទៅបានប្រកបដោយសង្គតិភាព និងលទ្ធផលជឿទុកចិត្តបាន គ្រប់មុខសញ្ញាអ្នកពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តតាមគំរូនៃការវាយតម្លៃសាលាមធ្យមសិក្សាដូចខាងក្រោម៖

**វិធីគណនា**

- ស្តង់ដាទី៥ មានសូចនាករវង់ចំនួន ៤
- ក្នុងចំណោមសូចនាករទាំង៤ អនុវត្តបាន ១៦ពិន្ទុ

ដូចនេះ វិធីគណនាជាភាគរយគឺ៖ ចំនួនសូចនាករដែលអនុវត្តបានទទួលបាន ១៦ពិន្ទុ ចែកនឹងចំនួនសូចនាករសរុបដែលមាន ២០ពិន្ទុអតិបរមា ហើយគុណនឹង ១០០។

ផ្អែកតាមការវាយតម្លៃខាងលើលទ្ធផលបានបង្ហាញថា សាលាមធ្យមសិក្សានោះអនុវត្តបានសម្រេច ១៦ពិន្ទុ លើ២០ពិន្ទុ ក្នុងចំណោមសូចនាករទាំង៤ នៃស្តង់ដាទី៥ ស្មើនឹង ៨០% មានន័យថា ទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូ។

## ៨. បែបបទនិងនីតិវិធីនៃការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ

### *៨.១. គោលការណ៍ទូទៅ និងលក្ខណៈវិនិច្ឆ័យ*

ការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ ផ្អែកលើវឌ្ឍនភាពនៃសាលាមធ្យមសិក្សា និងត្រូវធ្វើនៅរៀងរាល់ឆ្នាំសិក្សានីមួយៗ។ លក្ខណៈវិនិច្ឆ័យ និងឧបករណ៍ស្វ័យវាយតម្លៃសាលាមធ្យមសិក្សាដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូជាឧបសម្ព័ន្ធនៃឯកសារនេះ។

ការទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ៨.២. យន្តការ បែបបទ និងនីតិវិធី

### ៨.២.១ សាលាមធ្យមសិក្សា

គណៈគ្រប់គ្រងសាលាមធ្យមសិក្សា ត្រូវសហការជាមួយគណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សា ធ្វើស្វ័យវាយតម្លៃ ឱ្យបានច្បាស់លាស់មុននឹងដាក់ពាក្យស្នើសុំការវាយតម្លៃតាមឋានានុក្រមដើម្បីទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូ។

នាយកសាលាមធ្យមសិក្សាត្រូវដាក់ពាក្យស្នើសុំជូនអភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីសុំការវាយតម្លៃទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូ។ សំណុំបែបបទសម្រាប់ដាក់ពាក្យស្នើសុំត្រូវមាន៖

- ពាក្យស្នើសុំវាយតម្លៃទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូ ....................០៣ច្បាប់
- របាយការណ៍ស្វ័យវាយតម្លៃ ....................................................................០៣ច្បាប់
- បញ្ជីវត្តមានប្រជុំស្វ័យវាយតម្លៃ ................................................................០៣ច្បាប់
- ដីការសម្រេចទទួលស្គាល់គណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សា ................០៣ច្បាប់
- រូបថតសន្លឹក ឬ រូបថតវីដេអូ នៃទីតាំង ទីធ្លា ថ្នាក់រៀន និងសកម្មភាពពាក់ព័ន្ធ

### ៨.២.២ រដ្ឋបាលក្រុង ស្រុក ខណ្ឌ

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតគណៈកម្មការវាយតម្លៃសាលាមធ្យមសិក្សា ដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានសមាសភាពដូចខាងក្រោម៖

- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ — ប្រធាន
- អភិបាលរងនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ — អនុប្រធាន
- នាយករដ្ឋបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ — សមាជិក
- ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សមាជិកអចិន្ត្រៃយ៍
- មន្ត្រីទទួលបន្ទុកការងារអប់រំមធ្យមសិក្សានៃការិយាល័យអប់រំ យុវជន និងកីឡា សមាជិក

សមាសភាពជាក់ស្តែងនៃគណៈកម្មការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សា ដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយដីការបស់អភិបាលនៃ គណៈអភិបាលក្រុង ស្រុក ខណ្ឌ។

គណៈកម្មការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សា ដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូថ្នាក់ក្រុង ស្រុក ខណ្ឌ មានភារកិច្ចប្រជុំវាយតម្លៃ និងចុះពិនិត្យផ្ទាល់ដល់ទីតាំងសាលាមធ្យមសិក្សា ដោយផ្ទៀងផ្ទាត់របាយការណ៍ស្វ័យវាយតម្លៃ លក្ខណវិនិច្ឆ័យនៃការវាយតម្លៃសាលាមធ្យមសិក្សា និងស្តង់ដា

សាលាមធ្យមសិក្សាគំរូ។ បន្ទាប់ពីបានវាយតម្លៃរួច អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍វាយតម្លៃបញ្ជូនមកមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដោយភ្ជាប់ឯកសារពាក់ព័ន្ធរួមមាន៖

- ពាក្យស្នើសុំវាយតម្លៃទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូ ....................០៣ច្បាប់
- តារាងលទ្ធផលតាមចំណាត់ថ្នាក់នៃការវាយតម្លៃរបស់គណៈកម្មការ ..................០៣ច្បាប់
- ដីកាតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃថ្នាក់ក្រុង ស្រុក ខណ្ឌ ............០៣ច្បាប់
- របាយការណ៍ប្រជុំវាយតម្លៃ.................................................................................០៣ច្បាប់
- បញ្ជីវត្តមានប្រជុំវាយតម្លៃ...................................................................................០៣ច្បាប់
- របាយការណ៍ស្វ័យវាយតម្លៃពីសាលាមធ្យមសិក្សា .........................................០៣ច្បាប់

### ៨.២.៣ មន្ទីរអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ ដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូថ្នាក់រាជធានី ខេត្ត ដែលមានសមាសភាពដូចខាងក្រោម៖

- ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត — ប្រធាន
- អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាទទួលបន្ទុកមធ្យមសិក្សា — សមាជិក
- ប្រធានការិយាល័យមធ្យមសិក្សាចំណេះទូទៅ — សមាជិកអចិន្ត្រៃយ៍
- ប្រធាន/តំណាងការិយាល័យបុគ្គលិក — សមាជិក
- ប្រធាន/តំណាងការិយាល័យគណនេយ្យ — សមាជិក
- ប្រធាន/តំណាងការិយាល័យអធិការកិច្ច — សមាជិក
- អនុប្រធានការិយាល័យមធ្យមសិក្សាចំណេះទូទៅ — សមាជិក

សមាសភាពជាក់ស្តែង នៃគណៈកម្មការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូថ្នាក់រាជធានី ខេត្ត ត្រូវកំណត់ដោយលិខិតបង្គាប់ការឬលិខិតឧទ្ទេសនាមរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡា។

ដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូថ្នាក់រាជធានី ខេត្ត គណៈកម្មការវាយតម្លៃសាលាមធ្យមសិក្សា មានភារកិច្ចប្រជុំពិនិត្យលើលទ្ធផលនៃការវាយតម្លៃរបស់អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយផ្ទៀងផ្ទាត់របាយការណ៍ស្វ័យវាយតម្លៃ លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ និងចុះពិនិត្យផ្ទាល់ដល់ទីតាំងជាក់ស្តែងក្នុងករណីចាំបាច់។ បន្ទាប់ពីបានវាយតម្លៃរួច ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍បូកសរុបការវាយតម្លៃបញ្ជូនមកក្រសួងអប់រំ យុវជន និងកីឡា ដោយភ្ជាប់ឯកសារពាក់ព័ន្ធរួមមាន៖

- ពាក្យស្នើសុំវាយតម្លៃទទួលស្គាល់ជាស្តង់ដាសាលាមធ្យមសិក្សាគំរូ ....................០៣ច្បាប់
- តារាងលទ្ធផលតាមចំណាត់ថ្នាក់នៃការវាយតម្លៃរបស់គណៈកម្មការ ..................០៣ច្បាប់
- លិខិតបង្គាប់ការឬលិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃថ្នាក់រាជធានី ខេត្ត.....០៣ច្បាប់

- របាយការណ៍ប្រជុំវាយតម្លៃ.....................................................................០៣ច្បាប់
- បញ្ជីវត្តមានប្រជុំវាយតម្លៃ.......................................................................០៣ច្បាប់
- សំណុំឯកសារវាយតម្លៃរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌ..........................០៣ច្បាប់
- របាយការណ៍ស្វ័យវាយតម្លៃពីសាលាមធ្យមសិក្សា .........................................០៣ច្បាប់

### ៨.២.៤ ក្រសួងអប់រំ យុវជន និងកីឡា

សមាសភាពជាក់ស្តែង និងតួនាទីភារកិច្ចរបស់គណៈកម្មការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ កំណត់ដោយសេចក្តីសម្រេចដោយឡែករបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៩. សេចក្តីសន្និដ្ឋាន

ស្តង់ដាសាលាមធ្យមសិក្សាគំរូជាឧបករណ៍សម្រាប់វាយតម្លៃដែលគ្រប់ភាគីពាក់ព័ន្ធ ដូចជារដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យ អប់រំ យុវជន និងកីឡាជាសេនាធិការ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា អាចយកទៅប្រើប្រាស់ក្នុងការវាយតម្លៃ ស្របតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យការអប់រំមធ្យមសិក្សា ឬប្រព័ន្ធផ្សេងទៀត ដើម្បីជាប្រយោជន៍ក្នុងការអភិវឌ្ឍសាលាមធ្យមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថាគ្រប់សាលាមធ្យមសិក្សាទូទាំងប្រទេស នឹងខិតខំអភិវឌ្ឍន៍ខ្លួន ឱ្យស្របតាមស្តង់ដាសាលាមធ្យមសិក្សាគំរូនេះ ដើម្បីពង្រឹងស័ក្តិសិទ្ធភាពនៃការអភិវឌ្ឍស្ថាប័ន ប្រកបដោយចីរភាព ឆ្ពោះទៅការលើកកម្ពស់គុណភាពការអប់រំមធ្យមសិក្សា ធានាបាននូវប្រសិទ្ធភាពនៃលទ្ធផលសិក្សារបស់សិស្សកាន់ តែប្រសើរឡើងអនាគតប្រែក្លាយជាពលរដ្ឋល្អ មានគុណសម្បទាពលរដ្ឋសកល សម្រាប់កសាងសង្គមសន្តិភាពនៃជាតិកម្ពុជាជានិរន្តន៍។

## ឧបសម្ព័ន្ធ

# ស្ដីពី
# បែបបទនិងនីតិវិធីនៃការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សាគំរូ

## I. ព័ត៌មានទូទៅ

| | |
|---|---|
| ១. រាជធានី ខេត្ត | ៖........................................................................ |
| ២. ក្រុង ស្រុក ខណ្ឌ | ៖........................................................................ |
| ៣. ឃុំ សង្កាត់ | ៖........................................................................ |
| ៤. សាលាមធ្យមសិក្សា | ៖........................................................................ |
| ៥. លេខកូដសាលារៀន | ៖........................................................................ |
| ៥. ឈ្មោះនាយក | ៖........................................................................ |
| ៦. លេខទូរស័ព្ទនាយក | ៖........................................................................ |
